OLD VERSION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jun-2015, 16:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី២៩០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រ៊ា រតនៈ

លោក សេង លាង

លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក អ៊ុំត សេង (2-TCW-804) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អ៊ុត សេង** (2-TCW-804)

សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី ....................ទំព័រ ៣
សួរដោយលោក វ៉ែន ពៅ ផ្តើមពី ....................ទំព័រ ១៥
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ២១
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ២៥
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី....................ទំព័រ ៤៤
សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ៥០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្ម អ៊ុត សេង បញ្ចប់ ហើយនិងបន្តផ្តើមស្តាប់សក្ខីកម្មសាក្សីបម្រុង ដែលមាន ដែលមានរហស្សនាម 2-TCW-887។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៣:២៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺលោក អ៊ុត សេង លោកមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះ មានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-887។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែក មុនពេលមកផ្តល់សក្ខីកម្ម។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដែលគាត់មានបញ្ហាសុខភាព ឈឺចង្កេះ ឈឺក្បាល មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។ ដោយមេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះខ្លាំង មិនអាចអង្គុយ --ពិបាកអង្គុយ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៦:១១]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំមានការសុំបំភ្លឺខ្លីមួយទេ។ សាក្សីបន្ទាប់គឺ TCW-887 គឺជាសាក្សីតែម្នាក់គត់សម្រាប់សប្តាហ៍នេះ ឬក៏យ៉ាងណា ពីព្រោះយើងខ្ញុំកត់សម្គាល់ឃើញថា TCW-855 ក៏ជាសាក្សីបម្រុងសម្រាប់សប្តាហ៍នេះផងដែរ។ អ៊ីចឹងសំណួរសួរ បន្ទាប់ពីសាក្សី 887 តើសាក្សី -- មានសាក្សីណាបន្ទាប់មកទៀតលោកប្រធាន?

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៨:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ ដោយសារអង្គជំនុំជម្រះមិនបានបញ្ជាក់ជូនឡើងវិញដោយសារអង្គជំនុំជម្រះបានជូនភាគី -- ជូនដំណឹងភាគីតាមរយៈអ៊ីម៉ែលរួចហើយ។ ហើយអ៊ីចឹងទេគឺនៅសប្តាហ៍នេះ យើងធ្វើសវនាការស្តាប់សក្ខីកម្មតែសាក្សីរូបនេះ ហើយនិងសាក្សីមួយទៀតដែលមានរហស្សនាម 2-TCW-887 ប៉ុណ្ណោះ។ ដោយសារស្ថានភាពនៃសាក្សីដទៃទៀតហ្នឹង គឺមានបញ្ហាផ្ទាល់ខ្លួនដែលគាត់មិនអាចមកចូលរួមបាននៅក្នុងសប្តាហ៍នេះ ហើយការពន្យារពេល -- សុំពន្យារពេលរបស់គាត់មានរយៈពេលយូរ អ៊ីចឹងអង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីសាជាថ្មីបន្ថែមទៀតចំពោះកិច្ចដំណើរការសវនាការ ដូចអង្គជំនុំជម្រះបានជម្រាបជូនអ៊ីចឹង គឺថានៅសប្តាហ៍ក្រោយ យើងបន្តធ្វើការសវនាការពិភាក្សាដេញដោលលើអង្គហេតុការដ្ឋាន ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ហើយចំពោះសាក្សីដែលពាក់ព័ន្ធនឹងអង្គហេតុទំនប់១មករាដែលនៅសេសសល់ យើងនឹងធ្វើនៅចុងបញ្ចប់។ បានន័យថាមុនពេលសម្រាកវិស្សមកាលរបស់តុលាការនៅចុងខែ៦។

បាទ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីបងប្អូនទាំងអស់ ទាំងនៅក្នុង ទាំងក្រៅបន្ទប់សវនាការ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ជម្រាបសួរលោក អ៊ុត សេង! កាលពីម្សិលមិញ -- នៅថ្ងៃបញ្ចប់ពីម្សិលមិញ គឺលោកបានរៀបរាប់នៅមួយចំនួននៅក្នុងចម្លើយរបស់លោក ហើយខ្ញុំគិតថាអ្វី -- អ្នកធ្វើការទាំងអស់នេះគឺថាត្រូវ

បានមេកងគេឲ្យតម្រង់ជួរឈរដើម្បីឲ្យអ្នកដទៃទៀតគឺថា អ្នកដទៃទៀតមើលកុំយកតម្រាប់តាម។ តើត្រឹមត្រូវអ៊ីចឹងទេ?

**លោក អ៊ុត សេង៖**

**ឆ៖** ពិតជាត្រឹមត្រូវ។

**ស៖** ហើយលោកក៏បានជម្រាបថាពួកគេមិនបានទទួលរងរបួសអ្វីធ្ងន់ធ្ងរនោះទេ។ ប៉ុន្តែទោះបីជារងរបួសស្រាលក៏ដោយ តើមានរងរបួសស្រាលហ្នឹងដោយរបៀបម៉េច? មានស្នាមកន្ទួល ឬក៏មានដាច់ដោយរបៀបណាមួយដែរ? សូមលោករៀបរាប់បន្តិច?

**ឆ៖** ធម្មតា គេវ៉ៃមានកន្ទួលស្លាកស្នាមបន្តិចបន្តួច តែជាការព្រមានតិចតួចប៉ុណ្ណោះ។

**ស៖** ហើយចំពោះលោក លោកមានអារម្មណ៍យ៉ាងម៉េចដែរនៅពេលដែលមេកងគេធ្វើយ៉ាងហ្នឹងដាក់ទៅលើពលករទាំងអស់ហ្នឹង? នៅពេលដែលគេវ៉ៃនឹងរំពាត់យ៉ាងហ្នឹង?

**ឆ៖** យើងមានការភ័យខ្លាចមួយចំនួនដែរ តែយើងធ្វើយ៉ាងណាគោរពអង្គការវិន័យក្នុងក្រុមក្នុងកងរបស់យើងទៅ គឺចប់។

**ស៖** ខ្ញុំក៏បានសួរថាតើលោកនិយាយជាមួយអ្នកធ្វើការជាមួយលោកអំពីការវាយនេះដែរ ហើយលោកបាននិយាយថាបញ្ហានេះគឺថាមិនអាចយកទៅនិយាយជាមួយនឹងអ្នកនៅធ្វើការជាមួយគ្នាបានទេ។ ហេតុម៉េចបានជាមិនអាចនិយាយបាន?

**ឆ៖** យើងមានសិទ្ធិមើលបាន តែនិយាយមិនបានទេ តែនិយាយគឺខុស។

[០៩:១២:៣០]

**ស៖** ហើយបើសិនណាជា ប្រសិនណាបើលោកនិយាយបញ្ហានេះជាមួយអ្នកដទៃ តើវាមានអ្វីកើតឡើង?

**ឆ៖** បើយើងនិយាយប្រាប់ ឬក៏និយាយលេខភាសាអស់ហ្នឹងជាមួយមិត្តភក្តិ យើងនឹងមានអារម្មណ៍ភ័យខ្លាចជារៀងរហូត។ ដូច្នេះ យើងមិនអាចនិយាយលេងផ្តេសផ្តាស។ និយាយរួមគឺដាំដើមគ។

**ស៖** ខ្ញុំសុំអានចម្លើយរបស់លោកគឺ ទំព័រជាភាសាខ្មែរ 00271407, អង់គ្លេស 00282355, ហើយបារាំង 00482932 ដល់ 33, នេះគឺដែលលោកនិយាយអំពីប្រជាជនដែលត្រូវគេវាយ គឺថាអ្នកទាំងនោះមិនមានអ្វីហូបចុកទេ។ ដូច្នេះ ពួកគាត់មិនមានកម្លាំងធ្វើការទេ។ តើលោកចង់និយាយថាម៉េចត្រង់ចំណុចនេះ?

**ផ៖** ធម្មតា អ្នកចូលក្នុងកងពិសេស របបគឺតិចជាងអ្នកដែលមិនមានកងពិសេស គឺថារបបតិចជាង របបហូបប្រចាំថ្ងៃ។

**ស៖** ដូច្នេះ របបអាហារគឺមានចំនួនតិចតួច ហើយការងារវិញគឺថាច្រើន។ តើត្រឹមត្រូវឬទេ?

**ផ៖** បាទ គឺការងារច្រើន។

**ស៖** ម្សិលមិញលោកក៏បានជម្រាបផងដែរថា លោកបានចូលរួមនៅក្នុងកិច្ចប្រជុំទិតៀន ហើយកងពិសេសសម្រាប់មនុស្សខ្ជិលនេះ ក៏ត្រូវគេលើកយកមកនិយាយនៅក្នុងអង្គប្រជុំផងដែរ។ តើគេមាននិយាយយ៉ាងម៉េចដែរនៅក្នុងកិច្ចប្រជុំទិតៀន ស្វ័យទិតៀនពាក់ព័ន្ធទៅនឹងកងពិសេស ខ្ជិលនេះ?

[០៩:១៥:00]

**ផ៖** ដូចជម្រាបក្នុងកងនីមួយៗ ចប់កម្មវិធីពេលល្ងាចម៉ោងប្រាំ ឬក៏ប្រាំកន្លះអីចឹង គឺគេហៅមួយកងហ្នឹងគឺ ប្រជុំរួម ទិតៀន ស្វ័យទិតៀន តែហាក់ដូចជាគ្មានសមាជិកណាមានមតិយោបល់ទេ ព្រោះអារម្មណ៍ភ័យខ្លាច។ ហើយគេប្រជុំច្រើនជាកណ្ដុបៗ តាមកងគេពេលល្ងាចហ្នឹង តែយើងមិនមានថាមិនមាន -- គេឲ្យសិទ្ធិនិយាយ តែយើងហាក់មិនហ៊ាននិយាយ ព្រោះចាំតែស្ដាប់ផែនការប្រធានកងទៅគឺចប់។

**ស៖** ហើយនៅក្នុងប្រជា -- ប្រជុំហ្នឹង តើប្រធានកងហ្នឹងនិយាយប្រាប់លោកអ្វី អំពីកងពិសេសដែលមានមនុស្សខ្ជិលៗនេះដែរទេ?

**ផ៖** ខ្ញុំមិនចាំ តែប្រជុំម្ដងៗគឺគេលើកទិតៀន ស្វ័យទិតៀនហ្នឹង ប្រាប់សមាជិកហាក់ដូចជាគំរាមឲ្យប្រឹង កុំមើលគេខាងណោះ យើងប្រឹងប្រែងធ្វើការ តែប៉ុណ្ណឹង។

**ស៖** ពាក់ព័ន្ធទៅនឹងការវាយនឹងរំពាត់ដែលលោកនិយាយគឺថា ពួកៗមានមេកងពីរនែសម្រាប់គ្រប់គ្រងកងពិសេស ពួកមនុស្សខ្ជិលនេះ ដែលមានមេកងស្រីម្នាក់ ប្រុសម្នាក់។ តើមានអាជ្ញាធរណាមួយគេមកបញ្ជាប់អំពើបែបនេះទេ?

**ផ៖** មិនដឹងដែរ អត់ដឹងទេ។ មិនដឹងទេការងារនេះ។

**ស៖** តើលោកដែលឮសូរកង មេកងដែលធ្លាប់ដាក់ទណ្ឌកម្មឬ វិន័យណាមួយទៅលើពួកពលករដែលខ្ជិលៗនេះទេ?

**ផ៖** មិនដែលឮទេ ព្រោះគេនៅឆ្ងាយៗពីគ្នាពេលប្រជុំ តែបើពេលវាយដំយើងអាចមើលទៅឃើញបាទ។

**ស៖** តើដែលឮសូរការប្រកាសតាមរយៈមីក្រូនៅតាមការដ្ឋានការងារ គឺដែលនិយាយថា មិនឲ្យមេកងប្រព្រឹត្តអំពើហ្នឹងមកលើពលករទេ?

**ឆ៖** មិនមានការផ្សាយ ឬក៏ផ្សព្វផ្សាយអ៊ីចឹងទេ ប៉ុន្តែមានជាបទចម្រៀង១– បទចម្រៀងរបស់បដិវត្តន៍។

**ស៖** តើសារបដិវត្តន៍ សារចម្រៀងបដិវត្តន៍ហ្នឹង ច្រៀងថាយ៉ាងម៉េច និយាយអំពីអ្វីដែរ? លោកអាចរៀបរាប់បន្តិចបានទេ?

**ឆ៖** បើខ្ញុំចាំគឺ ការតស៊ូរបស់យុទ្ធមិត្តទាំងឡាយ ដែលមកវាយនៅសមរភូមិមុខ ដែលជារាល់ដងគេចាក់ យុទ្ធមិត្ត សាយ នៅ១តាមការដ្ឋានហ្នឹង។ យុទ្ធមិត្ត សាយ វាយត្រពាំងព្រីងអ៊ីចឹងទៅ។ ខ្ញុំចាំបានតែប៉ុណ្ណឹង។

[០៩:១៩:៣៨]

**ស៖** ខ្ញុំសូមចូលទៅប្រធានបទនិយាយអំពីការបាត់ខ្លួននៅពេលធ្វើការនៅពេលយប់ ពីម្សិលមិញលោកឡើងជាញឹកញាប់ ប៉ុន្តែខ្ញុំសូមចូលចំណុចនេះឲ្យបានលម្អិតបន្តិច។ ខ្ញុំសូមចាប់អានសម្រង់ចេញពីចម្លើយរបស់លោកនៅត្រង់ទំព័រ 00271408 ខ្មែរ, អង់គ្លេស 00282355 និងបារាំង 00482933។ នេះគឺជាអ្វីដែលលោកនិយាយ។ សូមដកស្រង់៖ "ការងារនៅពេលយប់ គឺជាការងារពិសេស ពីព្រោះមនុស្សបាត់ខ្លួននៅពេលយប់ ពីកងផ្សេង១។ ខ្ញុំឃើញគេហៅមនុស្សចេញទៅបាត់នៅពេលយប់ ហើយនៅព្រឹកឡើង ខ្ញុំឮសូរថាមនុស្សទាំងនោះត្រូវបានគេសម្លាប់ចោល។ អ្នកដែលត្រូវបានគេហៅខ្លួនយកទៅបាត់នៅពេលយប់នោះ គឺថាមិនដែលមិនបានឃើញត្រឡប់មកវិញទេ ហើយនៅការដ្ឋានធ្វើការងារនៅពេលយប់ ប្រសិនបើគេហៅមនុស្សទៅឆ្ងាយពីកន្លែងធ្វើការបន្តិច ប្រហែល១០ម៉ែត្រ នោះយើងមិនអាចមើលឃើញនោះទេ ហើយវាជាការងាយស្រួលក្នុងការចាប់មនុស្ស។ ពេលនោះ ខ្ញុំមានការភ័យខ្លាចណាស់ មិនដឹងថា ថ្ងៃណាដល់វេនរបស់ខ្ញុំនោះទេ"។ បញ្ចប់ការដកស្រង់។ ពីម្សិលមិញ ខ្ញុំឮសូរលោកនិយាយថា ចំណុចនេះគឺកើតឡើងតែម្តង ដែលលោកនៅចាំបាន តើវាពិតជាការបាត់ខ្លួននេះ វាពិតជាកើតឡើងតែម្តង ឬក៏អាចលើសពីនេះ?

[០៩:២១:២៧]

**ឆ៖** តាមខ្ញុំចាំគឺជួបកាលនុ៎ង កងរបស់ខ្ញុំកាប់ជិតកងរបស់ប្រជាជន គឺថាប្រជាជនភូមិថ្មីដែលមាន -- ប្រជាជនភូមិថ្មី និយាយរួម ពួក១៧មេសា មួយក្រុមហ្នឹង គឺជាមានអ្នកជាប់និន្នាការ

ជាទាហាន ជាស្ទីៗច្រើន ក្នុងដែលជាប់និន្ទាការ។ យើងកាប់ដីជិតគ្នាអ៊ីចឹងទៅ ដល់យប់ ស្រាប់តែមានឈ្លបហៅពីរបីនាក់ ចេញទៅក្រៅ យើងបានឃើញ យើងចាប់អារម្មណ៍ថាប្រាកដជាមានបញ្ហា។ គ្រាន់ថាយកទៅសម្លាប់ត្រង់ណានោះ យើងមិនដឹងទេ។ គ្រាន់តែដឹងថាចេញទៅ គឺមានបញ្ហា ប៉ុណ្ណឹង។

**ស៖** ហើយអ្វីដែលលោកបាននិយាយនោះ គឺនៅព្រឹកឡើង លោកឮថាគេសម្លាប់មនុស្ស និងទម្លាក់ចូលទៅក្នុងអណ្តូង។ តើលោកឮពីអ្នកណាមក?

**ឆ៖** វាជាចៃដន្យ ប្រធានវរយុវជន។ ក្នុងនោះវាមានឈ្លបសម្រាប់វរៈ សុទ្ធតែអ្នកវៃប្រហារហ្នឹង។ អ៊ីចឹង វានិយាយលែងគ្នាទេ តែយើងដើរកាត់ទៅឮ ក៏ថា "គេចូលអណ្តូងហើយ អាប៉ុន្មាននាក់យប់មិញ" គឺប៉ុណ្ណឹង។

**ស៖** ហើយការសន្ទនានេះ គឺរវាងមេកង ហើយនិងឈ្លប។ តើអ៊ីចឹងមែនទេ?

**ឆ៖** ប្រាកដមែន។

**ស៖** តើលោកដឹងថា មនុស្សប៉ុន្មាននាក់ ត្រូវបានគេនាំខ្លួនយកទៅបាត់នៅពេលនោះ?

**ឆ៖** មិនច្បាស់លាស់។ គ្រាន់តែឃើញដើរចេញពីរបីអ៊ីចឹងទៅ គឺយើងមានការព្រួយបារម្ភខ្លួនឯងបាត់ហើយ យើងនៅស្ងៀម។

[០៩:២៤:០៥]

**ស៖** ពីម្សិលមិញលោកក៏និយាយ ខ្ញុំសូមដកស្រង់៖ "គឺថាខ្ញុំមានការភ័យខ្លាចណាស់ មិនដឹងពេលណាដល់វេនរបស់ខ្ញុំនោះទេ"។ ហេតុអ្វីបានជាលោកភ័យខ្លាចថាមិនដឹងជាពេលណាដល់វេនលោក?

**ឆ៖** ជាទូទៅយើងរស់មួយថ្ងៃសម្រាប់មួយថ្ងៃ។ ព្រឹកឡើង យើងនៅរស់ យើងរស់បានមួយថ្ងៃ។ គឺប៉ុណ្ណឹង។

**ស៖** លោកក៏បាននិយាយថា មនុស្សដែលឈ្លបហៅយកទៅបាត់នោះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា នៅការដ្ឋានការងារហ្នឹង តែងតែមានវត្តមានឈ្លប ឬក៏យោធាជាប្រចាំ ឬក៏យ៉ាងណា?

**ឆ៖** យើងមិនអាចថាអ្នកនោះជាឈ្លប ឬក៏ជាអីទេ ព្រោះជាសម្លៀកបំពាក់ខ្មៅៗដូចគ្នា។

**ស៖** តើមានកងទ័ពប្រកបទៅដោយអាវុធ មានកងទ័ពទាំងពីរ កងទ័ពនារីបុរសស្ពាយអាវុធនៅការដ្ឋានការងារដែរឬទេ?

**ឆ៖** គ្មានកងទ័ពប្រដាប់ដោយកាំភ្លើង ឬ-- គឺខ្លួនទទេ។ ហើយយើងមិនអាចមើលថា អ្នកណាជាអ្នកជាឈ្លប ឬក៏ជាស្ទីនោះ យើងមិនអាចដឹងទេ។

[០៩:២៦:១៤]

**ស៖** ខ្ញុំសូមចូលទៅផ្នែកមួយនៃកិច្ចសម្ភាសន៍របស់លោក ហើយខ្ញុំសូមដកស្រង់ នឹងសួរសំណួរលោកទៅតាមក្រោយ។ ទំព័រគឺជាភាសាខ្មែរ 00271410 និងអង់គ្លេស 00282356 និងបារាំង 00482934 ទៅ 35 ហើយខ្ញុំអានទាំងសំណួរនិងចម្លើយ។ លោកត្រូវបានសួរ សូមដកស្រង់ "ហេតុអ្វីបានជាលោកមានការភ័យខ្លាចប្រចាំខ្លាចគេចាប់ខ្លួន? ហើយនេះជាចម្លើយ ខ្លាចសម្លាប់ ពីព្រោះថាបើយើងមិនធ្វើការ ធ្វើការមិនជិតដល់ គេចាត់ទុកយើងជាមនុស្សខ្ជិល យើងត្រូវត្រៀមខ្លួននឹងស្លាប់ទៅហើយ នៅក្នុងសង្កាត់មានសន្តិសុខ មានការតាមដាន ហើយគេកាន់ដំបង និងកាំបិត ហើយកាំបិត គឺពោរពេញទៅដោយឈាមកង ដូច្នេះ គឺយើងខ្លាចស្លាប់ដោយខ្លួនឯងតែម្តង"។ បញ្ចប់ការដកស្រង់។

តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ នៅពេលណាដែលលោកឃើញសន្តិសុខទាំងអស់ហ្នឹងមានកាន់ដំបង កាំបិត?

**ឆ៖** មួយរយៈនៅការដ្ឋាន ១មករា មិនទាន់ចប់ ខ្ញុំបាន -- ប្រធានសហករណ៍សុំដកចេញមកនៅភូមិ។ នៅភូមិ គឺយើងបានជួបស្និទ្ធញឹកញយ និយាយទៅជួបញឹកញយជាមួយពេជ្ឈឃាដដែលឈ្មោះលន់ ហ្នឹង ព្រោះគាត់នៅភូមិកងសៅខ្ញុំហ្នឹងផ្ទាល់ ហើយកងគាត់ គឺមានសៀតដាវ និងដំបងហ្នឹងជាប្រចាំ ដែលគួរឲ្យព្រឺខ្លួន។

**ស៖** តើលោកដឹងតួនាទីរបស់បុគ្គលដែលលោកទើបរៀបរាប់នេះទេ ហើយតើគាត់ស្ថិតនៅក្នុងកងមួយណាដែរ?

**ឆ៖** និយាយទៅ គាត់ជាមេឈ្លបប្រចាំឃុំ ប្រចាំសង្កាត់កំពង់ថ្ម ហើយបុគ្គលិកគាត់ប៉ុន្មាននោះខ្ញុំពុំបានដឹងទេ។ ឃើញ ស្គាល់គាត់ច្បាស់តែម្នាក់។

[០៩:២៩:២១]

**ស៖** ក្រៅពីឧទាហរណ៍ជាក់លាក់មួយនេះ តើលោកឃើញសន្តិសុខដទៃទៀត កាន់អាវុធ កាន់ដំបង ឬក៏កាំបិតដែរទេ?

**ឆ៖** ក្រៅពីនោះ មិនមានកាន់ដំបង ឬកាំបិតអី។

**ស៖** ហើយលោកបាននិយាយថា៖ "កងសន្តិសុខហ្នឹង គឺថាជាអ្នកធ្វើការតាមដាន" តើលោកចង់និយាយថាម៉េចជាអ្នកធ្វើការតាមដាននេះ?

**ឆ៖** បើនៅក្នុងភូមិមួយៗ គឺមានឈ្លបសម្ងាត់សម្រាប់តាមដានក្រោមផ្ទះ និយាយរួមឲ្យតែ

ពេលយប់ គឺមានសកម្មភាពគេតាមដានប្រជាជន ភាគច្រើនប្រជាជន១៧មេសា។ គេតាមដានពីពាក្យសម្ដី សកម្មភាព ការលួចដាំបាយ ដាំបបរ គឺសកម្មភាពអស់ទាំងហ្នឹង។

**ស៖** ខ្ញុំនឹងចូលនិយាយបុគ្គលម្នាក់ដែលមានឈ្មោះ លន ហើយខ្ញុំសូមអានចម្លើយរបស់លោកដែលនិយាយអំពីឈ្មោះបុគ្គលនោះ ទំព័រជាភាសាខ្មែរ គឺ 00271440, អង់គ្លេស 00282357 និងបារាំង 00482935 ហើយនេះគឺអ្វីដែលលោកនិយាយអំពីបុគ្គលរូបនេះ៖ "មានមេឃាតករម្នាក់ឈ្មោះ លន់ គាត់មានកង់ ហើយគាត់តែងតែ -- គាត់ដែលមានដាវ" ហើយលោកនិយាយថា "នៅឆ្នាំ១៩៧៩ ពេលវៀតណាមចូលមកដល់ ឈ្មោះលន់ ហ្នឹងត្រូវបានគេចាប់ដាក់គុក។ អ៊ីចឹងហើយបានជាគាត់នៅរស់រានមានជីវិត។ បើមិនដូច្នេះទេ គឺថាប្រជាជនគឺថាប្រាកដជានឹងសម្លាប់គាត់ចោលហើយ។ ហើយគាត់ទើបតែស្លាប់ប៉ុន្មានឆ្នាំមុននេះទេ។ ហើយក្នុងពេលនេះ គាត់គឺជាមេឈ្លបនៅសង្កាត់កំពង់ថ្ម"។ នៅក្នុងសម្រង់មួយនេះ គឺលោកនិយាយសំដៅគាត់ ហៅគាត់ថាជាមេឃាតករ បាទជាមេឃាតករ។ ហេតុអ្វីបានជាលោកអាចហៅគាត់ថាជាមេឃាតករអ៊ីចឹង?

**ឆ៖** ព្រោះគាត់ជាមេឈ្លប នៅក្នុងសង្កាត់កំពង់ថ្ម ហើយការសម្លាប់គឺគាត់ ដូចខ្ញុំនិយាយអ៊ីចឹង គឺថាមានដាវ មានដំបងប្រឡាក់ឈាមដាក់តាមកង់ គឺដូចគំរាមអ្នកដទៃឲ្យខ្លួនខ្លាចអ៊ីចឹងដែរ។ ប៉ុណ្ណឹង។

[០៩:៣៣:១៦]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ លោកហៅគាត់ថាជាមេពេជ្ឈឃាដ ដោយសារលោកឃើញគាត់មានឧបករណ៍ទាំងអស់ហ្នឹង ហើយឧបករណ៍ទាំងអស់ហ្នឹង គឺថាវាមានប្រឡាក់ទៅដោយឈាមផងយ៉ាងដូច្នេះឯងបានជាលោកហៅគាត់ជាមេពេជ្ឈឃាដ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺមែន។

**ស៖** ហើយលោកបានហៅគាត់ថា លោកដឹងថាគាត់ជាមេឈ្លបសង្កាត់កំពង់ថ្ម។ ហេតុអ្វីបានជាលោកដឹងថាគាត់ជាមេឈ្លបសង្កាត់កំពង់ថ្ម?

**ឆ៖** ព្រោះនៅក្នុងឃុំកំពង់ថ្ម គឺមានតែគាត់មួយ គឺមានតែគាត់ម្នាក់ហ្នឹងដែលបង្ហាញពីឥទ្ធិពល បង្ហាញពីថាភាពខ្លាំងក្លា ដែលមានដំបង មានដាវ ជាអ្នក ជាមេពេជ្ឈឃាដ។ គាត់បង្ហាញចរិតជាអ្នកខ្លាំងក្លា។

**ស៖** តើលោកធ្លាប់បានឃើញគាត់នៅទំនប់១មករាដែរទេ ឬក៏ថាគាត់ធ្លាប់បានទៅទំនប់មករាញឹកញាប់ដែរទេ?

**ឆ៖** គាត់មិនសូវទៅខាងទំនប់១មករា គាត់គឺច្រើននៅតាមភូមិដែលមានប្រជាជន១៧មេសាច្រើនៗ គាត់នៅតាមដានតាមភូមិច្រើនជាង នៅទំនប់១មករា។

[០៩:៣៥:០០]

**ស៖** តើលោកមានដឹងតួនាទីរបស់គាត់ណាមួយនៅក្នុងការចាប់មនុស្សទេ?

**ឆ៖** មិនដឹងទេ។ យើងមិនដឹងថា គាត់មានតួនាទីត្រឹមណាៗ ប៉ុន្តែបើសម្លឹងទៅគឺគាត់លេចធ្លោនៅក្នុងសង្កាត់កំពង់ថ្ម។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារមួយទៅសាក្សី គឺឯកសារ D166/156 ខ្ញុំជឿថាឯកសារនេះគឺមានការរៀបរាប់ពីឈ្មោះមនុស្សដែលសាក្សីទើប-- កំពុងតែរៀបរាប់នេះឯង។ ហើយយើងខ្ញុំសូមឲ្យគាត់មើលព័ត៌មានពាក់ព័ន្ធទៅនឹងបុគ្គលនេះនៅក្នុងឯកសារមួយនេះ ដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើបុគ្គលនៅក្នុងឯកសារនេះជាបុគ្គលដែលគាត់កំពង់តែនិយាយនេះ ឬក៏យ៉ាងណាដែរ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[០៩:៣៦:៤៦]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណើសុំបង្ហាញឯកសារមួយនេះទៅសាក្សី។ ទី១ គឺដោយសារថា គាត់មិនមានការដឹងអ្វីអំពីឯកសារនេះទេ ហើយសំខាន់ជាងនេះទៅទៀតគឺថា យើងដឹងថា លន់ មិនមានវត្តមាន ឬក៏ពាក់ព័ន្ធអីទៅនឹងទំនប់១មករានោះទេ។ ដូច្នេះ សាក្សីរូបនេះគ្មានអ្វីត្រូវនិយាយពីឈ្មោះ លន់ នោះទេ។ ហើយវាក៏មិនស្ថិត -- បើបុគ្គលនេះមិននៅទីនោះទេ វាក៏មិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងដំណាក់កាលកំពុងជំនុំជម្រះនេះដែរ។ ហើយប្រសិនណាបើគាត់មានវត្តមាននៅទំនប់១មករា មិនជាអ្វីទេ ក៏ប៉ុន្តែបើសាក្សីថាមិនមានទៅហើយ បើតាំងសំណួរបែបនេះគឺវាស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះនេះ។

**លោក ត្រាវីស ហ្វារ៖**

ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ ទី១ យើងខ្ញុំជឿជាក់ថា បុគ្គលរូបនេះ គឺជាសាក្សីដែលត្រូវចូលខ្លួននៅពេលក្រោយ។ ហេតុដូច្នេះឯងគឺថាវាសំខាន់ណាស់ ដែលត្រូវសាកសួរថា តើបុគ្គលដែលសាក្សី

កំពុងនិយាយ ជាសាក្សីនៅក្នុងឯកសារដែលនឹងត្រូវមកបន្ទាប់ឬក៏អត់? ហើយដោយសារតែវាមានផ្នែកមួយជាប់ពាក់ព័ន្ធផងដែរ។

ទំនាក់ទំនងរវាងសំណើរបស់យើងខ្ញុំ គឺវាពាក់ព័ន្ធរវាងឃុំមួយនេះទៅនឹងទំនប់ -- ទៅនឹងការដ្ឋានការងារហ្នឹង វានៅជិតគ្នា។ ហើយឃុំនេះក៏នៅជិតសង្កាត់នេះ។ ដូច្នេះអ្វីៗដែលវាកើតឡើងពេលនោះក៏ដូចជាកើតឡើងនៅក្នុងមួយនេះផងដែរ។

**លោក វិចទ័រ កូប៉េ៖**

សូមបញ្ជាក់កំណត់សម្គាល់ទី១ ខ្ញុំសូមអធ្យាស្រ័យ គឺថានៅពេលណា ឈ្មោះ លន់ ត្រូវមកផ្តល់សក្ខីកម្ម?

[០៩:៣៨:៤៧]

**លោក ត្រាវីស ហ្វារ៖**

គាត់ជាសាក្សី 2-TCW-830។ អ៊ីចឹងឯងបានជាខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញឯកសារនេះជូនទៅសាក្សីពិនិត្យមើល។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមខ្ញុំស្តាប់សក្ខីកម្មរបស់សាក្សីអម្បាញ់មិញនេះ និយាយអំពីឈ្មោះ លន់ ហាក់ដូចជា លន់ នោះផ្សេងពីឈ្មោះ លន់ ដែលជាសាក្សី ដែលត្រូវឡើងមកក្រោយ។ ដោយសារសាក្សីបានបញ្ជាក់ថា ឈ្មោះនោះស្លាប់បាត់ទៅហើយពីរបីឆ្នាំមុន។ ដូច្នេះ ខ្ញុំមិនដឹងថាជាបុគ្គលតែមួយ ឬវាជាមនុស្សផ្សេងគ្នា។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងបញ្ជាក់មើល៍ថា តើអន្តរជាតិ -- ស្តាប់ -- លន់ ដែលមានបំណងបង្ហាញឯកសារដែលពាក់ព័ន្ធចំពោះសាក្សីនេះ ជាមួយនឹង លន់ ដែលសាក្សីឆ្លើយអម្បាញ់មិញនេះ ជាមនុស្សតែមួយ ឬយ៉ាងម៉េច?

**លោក ត្រាវីស ហ្វារ៖**

ខ្ញុំជឿងជាក់ថាជាបុគ្គលតែមួយ ប៉ុន្តែមានតែសាក្សីទេ ទើបអាចជម្រាបជូនអង្គជំនុំជម្រះបាន

នៅពេលដែលគាត់ឃើញឈ្មោះពេញ។ ថាតើ -- កាលណាឃើញទាំងនាម និងគោត្តនាមទៅ គឺថាគាត់សាក្សីអាចនឹងបញ្ជាក់បាន។ ខ្ញុំមិនអាចឆ្លើយបានថា តើបុគ្គលដែលបានផ្តល់ចម្លើយនេះ គឺជាបុគ្គលតែមួយដែលសាក្សីកំពុងតែរៀបរាប់នេះ ឬក៏យ៉ាងណានោះទេ លោកប្រធាន។

[០៩:៤០:៣១]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤១:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី ក្នុងការដែលសហព្រះរាជអាជ្ញារងអន្តរជាតិ ស្នើសុំបង្ហាញឯកសារចំពោះសាក្សី ហើយអង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ហើយនិងបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការយកឯកសារដាក់ជូនសាក្សីពិនិត្យ។ ហើយសាក្សីកុំចាំបាច់បង្ហាញឈ្មោះជាសាធារណៈអី គ្រាន់តែអានទៅ ហើយផ្តល់ព័ត៌មានតាមសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ ហើយសូមរំឭកសហព្រះរាជអាជ្ញារងអន្តរជាតិថា សហព្រះរាជអាជ្ញារងអន្តរជាតិ រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយព្រឹក -- មួយៗ*សេសសិន* –មួយវគ្គ– នៃសវនាការនេះប៉ុណ្ណោះ។ ដូច្នេះ នៅពេលវេលាតែ៣០នាទីទេ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោក អ៊ុំត សេង លោកសូមលោកមើលឈ្មោះនៅក្នុងឯកសារដែលយើងគូសពីក្រោមនុ៎ងសូមលោកកុំបញ្ចេញអត្តសញ្ញាណរបស់គាត់ គ្រាន់តែបញ្ជាក់ប្រាប់ខ្ញុំមកថាតើឈ្មោះហ្នឹងមែនទេ ដែលជាលោក -- ជាឈ្មោះដែលលោករៀបរាប់អម្បាញ់មិញនេះ?

**លោក អ៊ុំត សេង៖**

**ឆ៖** ពិតប្រាកដមែន។

**ស៖** សូមអរគុណ។

**លោក ត្រាវីស ហ្វារ៖**

ឥឡូវនេះ សូមយកឯកសារពីសាក្សីមកវិញ។

សូមអរគុណលោកប្រធាន។

[០៩:៤៤:២២]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោក អ៊ុត សេង ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទផ្សេង គឺខ្ញុំនិយាយអំពីវត្តបារាយណ៍ជាន់ដែក។ តើលោកអាចជម្រាបខ្ញុំបានទេថា នៅពេលដែលលោកធ្វើការនៅទំនប់១មករាហ្នឹង គេយកវត្តបារាយណ៍ជាន់ដែកហ្នឹង ធ្វើជាកន្លែងអ្វីដែរ?

**ឆ៖** កាលជំនាន់នោះ ខ្ញុំបាទមិនច្បាស់ មិនដឹងទេ ពីព្រោះវត្តបារាណ៍ជាន់ដែក ដឹងគឺចាប់៧៩ ដែលដឹងថាវត្តបារាយណ៍ជាន់ដែក ជាកន្លែងសម្លាប់មនុស្ស។

**ស៖** អ៊ីចឹងនៅពេលឆ្នាំ៧៩ ហ្នឹងលោកដឹងដោយរបៀបណាថា វត្តហ្នឹងជាកន្លែងសម្លាប់មនុស្ស?

**ឆ៖** ដឹងដោយសារប្រជាជនដែលថាយើងទៅខ្វេះកកាយរកមាសពីសាកសពក្នុងវត្តដ៏ច្រើន។

**ស៖** តើលោកចង់មានន័យថាម៉េចនៅពេលដែលលោកនិយាយថាគេជីកគាស់ផ្នូរដើម្បីរកមាសហ្នឹង?

**ឆ៖** ឆ្នាំ៧៩ ប្រជាជននៅភូមិបារាយជាន់ដែក ឬក៏មកពីភូមិណាៗហ្នឹង គេៗទៅជីកៗខ្មោចទៅវាររកខ្មោចក្នុងរណ្ដៅហ្នឹង ដើម្បីរកមាស រកវត្ថុមានតម្លៃ។ ដល់អ៊ីចឹងទៅបានយើងបានដឹង និងល្បីដោយសារគាត់ទៅរកបានជាមាសមែន។

**ស៖** ខ្ញុំចង់អានទូវឃ្លាមួយដែលលោកបានលើកឡើងគឺ 00271409 ជាភាសាខ្មែរ, ជាភាសាអង់គ្លេស 00282356 -- 55-56, ជាភាសាបារាំង គឺ00482934។ "មានកន្លែងកប់សាកសពមនុស្សនៅវត្តបារាយជាន់ដែក គេចាក់ភ្លេងនៅពេលដែលគេសម្លាប់មនុស្ស គឺកន្លែងនោះហើយដែលជាកន្លែងដែលគេសម្លាប់មនុស្សនោះ"។ តើលោកអាចជម្រាបបានទេ ហេតុអ្វីបានជាលោកដឹងថាគេសម្លាប់មនុស្សនៅក្នុងវត្តនោះ?

[០៩:៤៧:៣៩]

**ឆ៖** កាលនោះ យើង -- ខ្ញុំបាទនៅខាងត្រើយខាងស្រុកសន្ទុក គឺម្ខាងៗដែលថា ម្ខាងស្ទឹងហ្នឹងវត្តបារាយជាន់ដែក ម្ខាងគឺខាងសន្ទុក។ គឺឮ ពេលមកឃ្វាលគោអ៊ីចឹង យើងឮមីក្រូស្រែកច្រៀងទ្រហឹងអឹងអាប់ទៅ ប៉ុន្តែយើងមិនដឹងថាគេធ្វើស្អីទេ ប៉ុន្តែអ្នកភូមិ ហៅថាអ្នកមូលដ្ឋានដែលឃ្វាលគោជាមួយយើងហ្នឹង គេថាតែមានចាក់មីក្រូអ៊ីចឹង គេវៃមនុស្សហើយ តែច្បាស់លាស់ដល់៧៩ ហ្នឹង គឺច្បាស់អ៊ីចឹងមែន ទៅឃើញរណ្ដៅធំៗ ហើយនិងសាកសព។

**ស៖** អ្នកដែលមើលគោក្របីហ្នឹង គាត់មានប្រាប់លោកថាគាត់ដឹងដោយរបៀបណាទេ ថានៅពេលដែលគេចាក់ភ្លេងតាមមីក្រូហ្នឹង គឺមានន័យថាគេកំពុងតែសម្លាប់មនុស្សហើយនោះ?

**ឆ៖** គាត់ថា គាត់មកឃ្វាលគោទីនេះរាល់ថ្ងៃ ឮមីក្រូ -- ពីរបីថ្ងៃឮមីក្រូ ហើយគាត់អាចថាគាត់ឮសម្រែកដែលថាវ៉ៃទៅស្មើរ គឺគេស្រែក។ គាត់និយាយបានតែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទចុងក្រោយ។ គឺខ្ញុំនិយាយអំពីគ្រួសារចាមដែលលោកបានរៀបរាប់នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺ ជាភាសាខ្មែរ 00271411, ជាភាសាអង់គ្លេស 00282357, ជាភាសាបារាំងគឺ 00482935។ ខ្ញុំសុំដកស្រង់នូវចម្លើយរបស់លោក៖ "ជនជាតិចាមក៏គេសម្លាប់ដែរនៅក្នុងភូមិភាគនោះ។ ថ្ងៃមួយខ្ញុំឃើញចាមនៅក្នុងភូមិរបស់ខ្ញុំបាត់ខ្លួន ហើយនៅក្នុងគ្រួសារ នៅក្នុងភូមិរបស់ខ្ញុំគឺមានគ្រួសារចាម ១០គ្រួសារ ហើយមានតែមនុស្សម្នាក់គត់ដែលនៅរស់"។ លោកក៏បានបញ្ជាក់ថា ពួកគាត់ហ្នឹងធ្វើការនៅក្នុងកងចល័ត។ តើលោកអាចរៀបរាប់ឲ្យបានលម្អិតអំពីគ្រួសារចាមទាំងនេះនៅក្នុងភូមិរបស់លោកបានទេ?

[០៩:៥០:៤៩]

**ឆ៖** នៅភូមិកងសៅខ្ញុំបាទហ្នឹងមានគ្រួសារជនជាតិចាមប្រហែលជា១០គ្រួសារ ប៉ុន្តែខ្ញុំមិនចាំស្ថិតិមនុស្សប៉ុន្មានទេ គ្រាន់តែថា ថ្ងៃមួយហ្នឹងវា ខ្ញុំបាទឃើញក្រមាអាវខោ ដូចថា គេបោះឲ្យតាមផ្ទះមួយៗសារុងចាម គ្រាន់តែឃើញយើងដឹងថារបស់ចាមហើយ។ រួចដល់ស្អែកឡើង ពេលទៅហូបបាយរួមហ្នឹងគឺមិនមានចាមទេ គឺអស់។ ហើយសរុបមក គ្រួសារចាមទាំង១០ហ្នឹង នៅសល់ម្នាក់ដែលបានទៅការដ្ឋានចល័តតំបន់ស្ទឹង -- ហៅថា ១មករាហ្នឹងនៅរស់។ ដាច់៧៩មក គឺនៅតែឯង ហើយមិនដឹងថាម្ដាយឪពុកស្លាប់ពីអង្កាល់ទេ អត់ដឹង។ ដាច់ ៧៩ គឺមកតែឯងអ៊ីចឹងទៅ ក៏បាត់មិនដឹងជាទៅណាមកណា នៅភ្នំពេញក៏មិនដឹង ឯណាមិនដឹង។ ប៉ុណ្ណឹង។

**ស៖** ក្រៅតែមនុស្សម្នាក់ដែលលោកជួបក្រោយឆ្នាំ៧៩ហ្នឹង តើលោកធ្លាប់ឃើញចាមផ្សេងទៀតនៅក្នុងភូមិរបស់លោកទៀតទេ នៅក្រោយឆ្នាំ១៩៧៩ហើយនោះ?

**ឆ៖** ៧៩ ដាច់មក គឺឃើញតែនារីម្នាក់នុ៎ងដែលនៅរស់ មករកឪពុកម្ដាយ ហើយក៏ចេញដំណើរបាត់ខ្លួនតាំងពីនោះ។ ក្រោយមកក៏គ្មានជនជាតិចាមអីដែលសេសសល់មកទៀតដែរ។

**ស៖** សូមអរគុណលោក អ៊ុត សេង។ លោកប្រធាន ខ្ញុំសុំអនុញ្ញាតប្រគល់វេទិកានេះជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

[០៩:៥៣:២៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ លោកប្រធាន ខ្ញុំសុំអនុញ្ញាតប្រគល់វេទិកានេះជូនសហភាតារបស់ខ្ញុំគឺលោកមេធាវី វ៉ែន ពៅ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោក វ៉ែន ពៅ!

**លោក វ៉ែន ពៅ៖**

បាន សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ជម្រាបសួរពូ អ៊ុត សេង។ ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរពូនៅពេលនេះ នៅពេលម៉ោងវគ្គចុងក្រោយនេះ។ សំណួរខ្ញុំជាដំបូងដែលត្រូវសួរពូ គឺពាក់ព័ន្ធទៅនឹងកំណត់ហេតុស្ដាប់ចម្លើយរបស់ពូដែលព្រះរាជអាជ្ញាបានសួរហើយ គឺដែលមានលេខឯកសារ E3/5267។ នៅក្នុង ERN ជាភាសាខ្មែរ 00271405, ERN ជាភាសាអង់គ្លេស 00282353, និង ERN ជាភាសាបារាំង 0048 2931។ នៅក្នុងសំណួរចម្លើយនោះគេបានសួរលោកថានៅពេលដែលលោកទៅដល់ស្រុកកំណើតវិញ តើគេឲ្យលោកធ្វើការអីខ្លះ? លោកបានឆ្លើយថា៖ "ខ្ញុំមកដល់ប្រហែលមួយសប្ដាហ៍ខ្ញុំត្រូវបានគេឲ្យជីកអាងនៅតាំងក្រសាំង។ ខ្ញុំមិនចាំថាតើខ្ញុំធ្វើការនៅទីនោះអស់រយៈពេលប៉ុន្មាននោះទេ។ ខ្ញុំធ្វើការនៅទីនោះជាច្រើនខែទាំងប្រាំងទាំងវស្សា"។ សំណួររបស់ខ្ញុំដែលត្រូវសួរពូថា តើពេលដែលពូទៅដល់ដំបូងនោះ តើគេចាត់ទុកពូជាមនុស្សប្រភេទណា? ជាប្រជាជនប្រភេទណាដែរបាទ?

[០៩:៥៥:០០]

**ឆ៖** ឆ្នាំ៧៥ ទៅដល់ដំបូង ហាក់ដូចជាមិនទាន់បែងចែកវណ្ណៈ ១៧ ឬក៏ ១៨ អីទេ គឺគេប្រមូល

កម្លាំង។ កាលហ្នឹងក៏មិនទាន់ហូបបាយរួមដែរ។ យើងមកត្រូវបានប្រធានភូមិចាត់តាំងឲ្យមកនៅ -- ឲ្យមកជីកស្រះ ជីកអាងនៅតាំងក្រសាំងអ៊ីចឹង ជាមួយប្រជាជនៗមូលដ្ឋាន–ប្រជាជនចាស់– ហើយយើង ១៧ មេសាហ្នឹង មានយុវជនបីបួននាក់ទៅជួយបំពេញកម្លាំងក្នុងភូមិ ប៉ុន្តែខ្ញុំមិនចាំខែថ្ងៃដែលខ្ញុំបានអនុវត្តការងារនៅទីនោះទេ។

**ស៖** បាទសូមអរគុណ។ ពាក់ព័ន្ធនឹងឯកសារមួយទៀត លោកប្រធានខ្ញុំសូម -- គឺឯកសារ D366/7.1.848 នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែរ។ លោកបានឆ្លើយថា "លុះៗដល់ឆ្នាំ ១៩៧៦ ឬឆ្នាំ១៩៧៧ សហករណ៍បានចាត់តាំងឲ្យខ្ញុំទៅធ្វើពលករៗលើកទំនប់ ១មករា ស្ថិតនៅភូមិកំពង់ថ្ម នៅស្រុកសន្ទុកខេត្តកំពង់ធំ។ ពលករដែលមកលើកទំនប់នោះមានចំនួន ច្រើនម៉ឺននាក់ ព្រោះទំនប់នេះជាទំនប់របស់ភូមិភាគ"។ សំណួរដែលខ្ញុំចង់សួរថាតើ ពូដឹងថាទំនប់នេះជារបស់ភូមិភាគដោយៗរបៀបណា? អ្នកណាអ្នកប្រាប់ពូ បាទ?

[០៩:៥៧:០៨]

**ប្រធានអង្គជំនុំ៖**

លោកកុំអាលទាន់ឆ្លើយតប។

**លោក អ៊ុត សេង៖**

**ឆ៖** និយាយរួមគឺ ឲ្យតែមានច្រើនតំបន់មកគឺជា គេហៅភូមិភាគ ដូចទំនប់ធំមួយៗ ល្បីៗ គេហៅទំនប់តំបន់ៗហ្នឹងគឺ ក្នុងខេត្តកំពង់ធំមួយ គេហៅទំនប់តំបន់ ដល់មានតំបន់៤២, ៤៣ អ៊ីចឹងមកគេហៅទំនប់ភូមិភាគ បូកសរុបមនុស្សវាច្រើនម៉ឺននាក់។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ សូមអរគុណ។ តើពូដឹងទេ តំបន់ -- ដែលថាទំនប់នៅក្នុងភូមិភាគ នៅភូមិភាគណា ហើយពូបានដឹង ឬមានអ្នកណាប្រាប់ពូថាមានដែលមានមេភូមិភាគ ឬប្រធានភូមិភាគ មកទស្សនកិច្ចតំបន់ -- ទំនប់ ១មករាហ្នឹងទេបាទនៅសម័យនោះ?

**លោក អ៊ុត សេង៖**

**ឆ៖** យើងៗដឹងដោយសារប្រព័ន្ធមីក្រូរាល់ថ្ងៃគឺ ចម្រៀងរបស់ភូមិភាគ៣០៤ ឬក៏តំបន់ ៤៣ ឬ ៤២ អ៊ីចឹងគឺយើង គេមានដែលថាផ្សព្វ គេផ្សព្វផ្សាយតិចតួច ថា ហ៎! ទំនប់ភូមិភាគ៣០៤ ឬភូមិភាគ ៣០៣ គឺយើងដឹងដោយខ្លួនឯង ឲ្យតែមានមនុស្សច្រើនគឺល្បី យើងដឹងយើងឮខ្លួនឯង។

**ស៖** បាទ សូមអរគុណបាទ។ ពាក់ព័ន្ធនឹងចម្លើយរបស់ពូបានឆ្លើយជាមួយនឹងសហព្រះរាជអាជ្ញាកាលពីម្សិលមិញដែរ ខ្ញុំចង់បញ្ជាក់បន្ថែម ពូបានឆ្លើយថា នៅក្នុងកងរបស់ពូដែលទៅពីភូមិពូនោះមានគ្នា៣០នាក់។ សំណួររបស់ខ្ញុំចង់សួរថាតើនៅក្នុងចំណោម ៣០នាក់ហ្នឹង ពួកពូប្រុសៗសុទ្ធ ឬក៏មានស្ត្រីលាយជាមួយដែរក្នុងចំណោម ៣០នាក់នោះ?

**ឆ៖** និយាយរួម មួយកង គឺមិនមែនចេញពីភូមិទៅ៣០នាក់ហ្នឹងទេ។ និយាយរួមកម្លាំងចេញភូមិទាំងប៉ុន្មានទៅប្រមូលផ្តុំដែលថា វរៈយុវជនហ្នឹង គឺចម្រុះភូមិក្នុងសង្កាត់ ឲ្យតែយុវជនទៅនៅវរៈទី២ យុវជនហ្នឹងគឺប្រមូលផ្តុំគ្នាបានហើយ បានគេចែកជាកង។ មិនមែនចេញពីភូមិទៅ -- ចេញពីភូមិ មានកម្លាំងស្រី កម្លាំងប្រុស នារីៗគេនៅវរៈទី៣ នារីអីចឹងទៅ មិនអាចជិតគ្នាបានទេ ប៉ះពាល់សីលធម៌។ គឺប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ហើយឆ្លើយតបទៅនឹងអ្វីដែលពូបានឆ្លើយពីម្សិលមិញដែរ ពូបានបញ្ជាក់ថា ការងារគឺគេចែកឲ្យពូធ្វើ ក្នុងបីនាក់ហ្នឹង ធ្វើជួនកាលឲ្យហើយពី១ម៉ែត្រគូបទៅ ១,៥ម៉ែត្រគូប។ តើផែនការគេដាក់ឲ្យពូធ្វើហ្នឹង បើសិនជាមានអ្នកធ្វើមិនហើយ តើគេឲ្យពូធ្វើតទៅពេលយប់ទៀតទេ ឬក៏យ៉ាងម៉េច?

**ឆ៖** និយាយរួមការងារក្នុងកង ផែនការទទួលពីវរៈមក ឧទាហរណ៍ថា ៣០ម៉ែត្រអីចឹង មួយកងហ្នឹងយើងចែកគ្នាទៅ បីក្រុម ៣០នាក់ហ្នឹង។ តាមពិត គ្រាន់ថា ១ម៉ែត្រគូប ឬក៏១,៥ម៉ែត្រគូបហ្នឹង វាជាការងារប្រចាំថ្ងៃរបស់យើង។ ប៉ុន្តែប៉ុណ្ណឹង យើងធ្វើរួចល្ងមត្រឹមម៉ោងប្រាំ ឬក៏ម៉ោងប្រាំកន្លះអី យើងធ្វើរួចល្ងម។

[១០:០០:៥៧]

**ស៖** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់សួរថាតើពូមានសង្កេតឃើញ បើអ្នកធ្វើមិនហើយវិញ ថាតើគេមានឲ្យធ្វើតទៀតដល់យប់ឬទេ?

**ឆ៖** សំខាន់ក្នុងកង គឺយើងត្រូវតែធ្វើឲ្យរួចជាមួយគ្នា ជួយគ្នា មិនប្រចាំការងារគ្នាទេ។ ចែកគ្នាចែកហើយ ប៉ុន្តែជួយគ្នាឲ្យរួចក្នុងកង។

**ស៖** បាទ សូមអរគុណ។ ហើយពីម្សិលមិញ ក៏ពូបានឆ្លើយផងដែរ ពាក់ព័ន្ធទៅនឹងគ្រោះថ្នាក់ការងារ ពូថាពូបានសង្កេតឃើញមានអ្នកធ្វើការនៅការដ្ឋាននោះខ្លះដែរ បានដួល ដោយសារហេវហត់អស់កម្លាំង។ សំណួរខ្ញុំ ចង់សួរថា តើពូសង្កេតមើលទិដ្ឋភាពអ្នកដែលដួលនោះ ដោយសារគាត់ធ្វើការ

ខ្លាំងហួសកម្លាំង ឬក៏ដោយសាររបបអាហារមិនគ្រប់គ្រាន់ បានគាត់ដួល?

**ឆ៖** ពីមួយថ្ងៃទៅមួយថ្ងៃ គឺកម្លាំងកាន់តែចុះខ្សោយ។ របបអាហារមិនគ្រប់គ្រាន់។ បើទៅបត់ជើងលែងស្ទុយ ហៅថា ដើរជើងមនុស្ស លាមកជ្រូក។

**ស៖** ពាក់ព័ន្ធនឹងរបបអាហារហ្នឹងដែរ ពូអាចបញ្ជាក់បានទេ តើមានអនាម័យ ឬក៏យ៉ាងម៉េចដែរ បញ្ហាអនាម័យនៅតំបន់ជុំវិញការដ្ឋានោះ ពូអាចបញ្ជាក់បានទេ?

**ឆ៖** និយាយរឿងអនាម័យ ហាក់ដូចជាពុំមានអនាម័យទេ ព្រោះរុយ ព្រោះបត់ដែបត់ជើងវាតាមវាលតាមកាល។

**ស៖** បាទ សូមអរគុណ។ ឆ្លើយតបនឹងសំណួរដែលគេបាន -- ដែលសហព្រះរាជអាជ្ញាបានសួរពូពីម្សិលមិញដែរ ពូបានឆ្លើយពាក់ព័ន្ធនឹងការសម្រាក។ ពូថា នៅពេលធ្វើការនោះ មានម៉ោងសម្រាក ម៉ោងសម្រាកតូចមួយ គឺសម្រាកមួយភ្លែតទេ ដល់ពេលការងារចប់ទៅ បានពូទៅសម្រាកនៅកន្លែងរោងដែលគេធ្វើទុកជូន។ ថាតើខ្ញុំសួរអំពីស្ថានរោងដែលគេធ្វើទុក នៅចម្ងាយប៉ុន្មានម៉ែត្រ ប៉ុន្មានគីឡូ ពីការដ្ឋានដែលពូកធ្វើនោះបាទ?

[១០:០៣:៤២]

**ឆ៖** បើសម្រាប់កង -- អ៎! វរយុវជនខាងខ្ញុំ វាប្រហែលជា១គីឡូ -- ២០០ម៉ែត្រ ឬ៣០០ម៉ែត្រពីការដ្ឋាន យើងត្រូវដើរមកហូបបបរ ពីកន្លែងរោងវិញ ហូបរួចយើងសម្រាកតែម្តង។

**ស៖** ពូអាចបញ្ជាក់បានទេ រោងនោះមានស្ថានបែបម៉េច ស្អាតបាតទេ ឬក៏រោងយ៉ាងម៉េច? ធ្វើអំពីអី? ហើយមាន -- នៅពេលសម្រាកពេលយប់ មានមុង ចែកមុង ចែកភួយអីឲ្យដែរទេបាទ?

**ឆ៖** រោង វាគ្រាន់បើតែដំបូល។ រាងដំបូល ដូចថា រោងប្រហែល១០០ម៉ែត្រ ដេកសងខាងគ្នាទល់ជើងគ្នាអីចឹង ជិតតែដំបូលទេ តែរនាបវាគឺកូនឈើវែងនឹងរពាក់ទៅ ដេកជិតៗគ្នាអីចឹងទៅ។ កម្មសិទ្ធិមានរៀងខ្លួន អ្នកណាគ្មានមុង គ្មានភួយ ក៏តាមដំណើរហ្នឹងទៅ ដេក។ កម្មសិទ្ធិសំខាន់គឺកាមែលដាក់បបរ និងស្លាបព្រា ធ្វើម៉េចកុំឲ្យបាត់។ ប៉ុណ្ណឹងកម្មសិទ្ធិ។ ចប បង្កី។

**ស៖** ពាក់ព័ន្ធនឹងរបបសម្លៀកបំពាក់ហ្នឹង តើគេចែកឲ្យពូដោយរបៀបណា មានសម្លៀកបំពាក់ ឬក៏ចែកជាស្បែកជើង ឬក៏ខោអាវប៉ុន្មានកំប្លេដែរ ក្នុងអំឡុងពេលពូទៅធ្វើការនៅទីនោះបាទ?

**ឆ៖** និយាយរួម ពួក១៧មេសា ពុំមានរបបអាវខោ ស្បែកជើង គ្មានទាល់តែសោះ។ ស្លៀកពីអាវវែងមកអាវដៃខ្លី ខោវែងមកខោខ្លី គឺមានតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។

លោកប្រធាន ខ្ញុំសូមអានលេខឯកសារមួយទៀត ពាក់ព័ន្ធនឹងចម្លើយរបស់គាត់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ គឺឯកសារ E3/5267 ដដែល គឺដែលមានលេខ ERN ជាភាសាខ្មែរ 00271407, ERN ជាភាសាអង់គ្លេស 00282354 និង ERN ជាភាសាបារាំង 00482932។

នៅក្នុងសំណួរពាក់ព័ន្ធនឹងគេសួរថា "នៅក្នុងក្រុមមួយៗ តើគេឲ្យលើកទំនប់ដូចម្ដេច?" ពូបានឆ្លើយថា "វាអាស្រ័យទៅលើទំហំដីក្នុងក្រុមមួយហ្នឹង គេលើក៣ម៉ែត្រគូប -- ៣ម៉ែត្រប្រឡាយ នៅពេលដែលគេចាត់ទុកថា យើងខ្ជិល គេនឹងយកទៅដាក់ក្រុមពិសេសមួយទៀតសម្រាប់អ្នកដែលខ្ជិល។ ប្រសិនបើមិនប្រឹងធ្វើការនោះទេ គេនឹងសម្លាប់ចោល"។ ខ្ញុំចង់សួរពូថាតើមុនពេលដែលគេចាត់ទុក ឬក៏គេចាត់ទុកថាយើងខ្ជិលនោះ តើគេមានហៅទៅអប់រំ ឬក៏ដាស់តឿនម្ដង ពីរដងទេ ឬក៏គ្រាន់តែថាគេសង្កេតឃើញយើងខ្ជិល គេយកទៅសម្លាប់ចោលតែម្ដងបាទ?

[១០:០៧:២៧]

**ឆ៖** និយាយទៅអ្នកៗ ថាខ្ជិលក៏បាន ព្រោះថាវាហេវ វាហត់ ដូចថាយើងទម្រន់នឹងការងារអ៊ីចឹងទៅ។ ម្យ៉ាងទៀត យើងដើរហើរខុសអង្គការវិន័យរបស់អង្គការអ៊ីចឹងទៅ គេប្រមូលគ្នាដាក់ក្រុមពិសេស បង្កើតកងពិសេសដែលមានទាំងនារី ទាំងកងយុវជនហ្នឹងឯង អាពិសេសហ្នឹង ហើយការងារពលកម្ម គឺគេប្រើជាងអ្នកមិនពិសេស។

**ស៖** បាទ សូមអរគុណ។ សំណួរខ្ញុំមួយទៀត ពាក់ព័ន្ធនឹងកុមារ។ តាមការសង្កេតរបស់ពូនៅការដ្ឋាននោះ ថាតើពូមានធ្លាប់សង្កេតឃើញមានក្មេងៗតូច ឬកុមារអាយុក្រោម១២, ១៣ឆ្នាំត្រូវបានទៅធ្វើការ ឬក៏ទៅធ្វើពលកម្មនៅទីនោះដែរទេ? ពូមានសង្កេតឃើញទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក អ៊ុត សេង៖**

**ឆ៖** និយាយរួមនៅការដ្ឋាន១មករា ការដ្ឋានធំៗ គ្មានកុមារចូលរួមជាមួយមនុស្សចាស់នោះទេ។ កុមារនៅដោយកុមារ ខាងនៅភូមិអ៊ីចឹងទៅ ដើររើសអាចម៍គោ ដើរកាប់ទន្រ្ទានខែត្រ វាមិនអាចចូលការដ្ឋានធំៗបានទេ។

[១០:០៩:១៥]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ពាក់ព័ន្ធនឹងរៀបការដោយបង្ខំ ខ្ញុំចង់សួរពូថា តើនៅក្នុងរបបខ្មែរក្រហមនោះ នៅក្នុងភូមិពូ ឬក៏នៅការដ្ឋាន ដែលពូមានបានឃើញ ឬក៏បានដឹងថា មានគេបង្ខំឲ្យរៀបការដែរទេ នៅក្នុងកងរបស់ពូ ហ្នឹងបាទ?

**ឆ៖** នៅក្នុងកង នៅវ័យយុវជន ឬក៏ពេលដែលត្រូវអង្គការរៀបឲ្យហ្នឹង គឺគេភាគច្រើនជាយុវជនមូលដ្ឋាន បើ១៧មេសា គឺមិនអាចៗថារៀបអីបានទេ។ បើមូលដ្ឋានចាស់គេអាច អង្គការហៅទៅរៀបនៅកន្លែងសង្កាត់អីអីចឹងទៅ ប្រាំគូ ១០គូអីចឹងទៅ។ ប៉ុន្តែមិនបានចូលរួមជាមួយអីចឹងៗទេ យើងគ្រាន់តែដឹងថា អូ៎! ថ្ងៃនេះមានអង្គការរៀបឲ្យមិត្តខាងយើងពីរបីនាក់ដែរ។ ដឹងអីចឹងបាទ ត្រង់បង្ខំ ឬមិនបង្ខំ យើងអត់ដឹង។

**ស៖** ជាសំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធនឹងមនុស្សស្លាប់។ ពូបានលើកថាធ្លាប់បានឃើញមានអ្នកស្លាប់ ឬក៏ត្រូវបានគេយកទៅសម្លាប់។ សំណួរខ្ញុំសួរថា តើបើនៅក្នុងភូមិ ក៏ដូចជានៅការដ្ឋាន បើមានអ្នកស្លាប់នោះ ថាតើគេមានឲ្យធ្វើបុណ្យ ធ្វើទានអីដែរទេនៅសម័យនោះ?

**ឆ៖** អ្នកដែលស្លាប់ គឺយើងមិនដឹងទៅសាកសពនៅឯណាផង គឺគ្មានសិទ្ធិធ្វើបុណ្យ ធ្វើទានទេ គ្រាន់តែយើងឈឺសុំ -- ម្តាយឈឺ យើងសុំមកមើល ក៏គេថាដែរ "ម៉េច មិត្តឯងពេទ្យ ចង់គេចការងារ!" អាហ្នឹងគឺយើងចង់ចូលរឿងមនុស្សខ្ជិល ចង់ចូលកងពិសេសទៀត គឺអីចឹង។ មិនមានសិទ្ធិ តែខ្មោចយើងមិនបានឃើញផង។

**ស៖** បាទ សូមអរគុណពូ។

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់កន្លះ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅមេធាវីការពារក្តី ដំបូងនេះជូនទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

អ៊ំ! សូមផ្អាកសិនលោក វិុចទ័រ កូប៉េ! លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានសំណួរបាទ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសួរតែពីរបីសំណួរទេ មិនយូរទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ជម្រាបសួរលោកសាក្សី ខ្ញុំសូមឱ្យលោកជម្រាបជូនតុលាការថា បើតាមលោកដឹងទំនប់១មករា -- តើទំនប់១មករា គឺជាទំនប់ដែលត្រូវបានលើកឡើងនៅលើស្ទឹងជីនិត ឬក៏ថាស្ថិតនៅក្នុងខេត្តកំពង់ធំ អ៊ីចឹងមែនទេ? គឺជាទំនប់ទី១ហើយ ដែលលើកនៅស្ទឹងជីនិតហ្នឹង ឬក៏មុនទំនប់១មករាហ្នឹងមានទំនប់អីផ្សេងទៀត ដែលគេបានលើករួចមកហើយ?

**លោក អ៊ុត សេង៖**

**ឆ៖** មុនទំនប់១មករា គឺមានទំនប់៣០កញ្ញា ដែលលើកមុនឆ្នាំគឺឆ្នាំ៧៧។ អាហ្នឹងជាទំនប់ -- មិនច្បាស់ដែរ ព្រោះខ្ញុំអត់បានទៅទេខាងណោះ។ ទំនប់១មករា ឆ្នាំ៧៨ ជាទំនប់ទី២។

**ស៖** អ៊ីចឹងគឺទំនប់១ទៀត ដែលលោកបាននិយាយអំមិញថាជា ១កញ្ញានោះ -- ៣០កញ្ញា គឺទំនប់ហ្នឹងលោកចង់និយាយគឺត្រូវបានលើកឡើងមុនឆ្នាំ១៩៧៥ ឬក៏ក្រោយឆ្នាំ១៩៧៥?

**ឆ៖** ទំនប់៣០កញ្ញា គឺក្រោយ៧៥។ ហើយយើងបានដឹងគឺបានដឹងឮឆ្នាំ៧៩-៨០ ដែលឮឈ្មោះនេះ។

**ស៖** បាទ គេនិយាយអំពីការសាងសង់ទំនប់ហ្នឹងច្រើន និយាយពីការងាររែកដី ហើយនិងជីកប្រឡាយជាដើម ក៏ប៉ុន្តែដើម្បីធ្វើទំនប់ត្រូវមានទ្វារទឹកចាក់បេតុង ហើយដើម្បីធ្វើទ្វារទឹកទាំងអស់នេះត្រូវការស៊ីម៉ង់ត៍ ឬក៏ត្រូវការសម្ភារៈជាដែកអីជាដើម ជាដែកថែប តើលោកធ្លាប់ឃើញគេធ្វើទ្វារទឹកអំពីបេតុង ឬស៊ីម៉ង់ត៍នេះដែរឬទេ?

[១០:៣៦:៣៤]

**ឆ៖** នៅជំនាន់នោះ យើងពុំមាន -- យើងមិនដឹងថាគេធ្វើស្អីខ្លះ ក្រៅពីកន្លែងដែលយើងធ្វើការកាប់ដីប៉ុណ្ណឹងទេ ហើយមិនដឹងថាគេធ្វើទំនប់ បេតុងហ្នឹងបានស្អីមកពីណា ស៊ីម៉ង់ត៍ដែកអីហ្នឹង ក៏យើងមិនដឹងថាគេ -- យើងមិនដឹង។

**ស៖** ហើយចុះអ្នកដែលគេចាត់ឲ្យធ្វើទ្វារទាំងអស់ហ្នឹង សុទ្ធតែជាអ្នកមានជំនាញ ឬក៏សុទ្ធតែជាអ្នកធ្វើការដែលចេញមកពីកងចល័ត ឬក៏ចេញពីតាមភូមិនៅក្បែរៗហ្នឹងទេ តើលោកដឹងរឿងហ្នឹងទេថាពួកគាត់មកពីខាងណាដែរ ហើយមានជំនាញដែរឬទេ?

**ឆ៖** បើតាមខ្ញុំបានឮ គេរើសកម្លាំងដែលមាំៗមិន -- និយាយរួមគឺកម្លាំងមកពីចម្រុះ កម្លាំងយុវជនដែលមាំៗ គេយកទៅធ្វើការនៅទីនោះ។ ត្រង់ជំនាញអីៗ យើងមិនដឹង។

**ស៖** ប្រហែលជាមានគេចោទសំណួរដែលខ្ញុំសួរទៅៗហើយ ទៅកាន់លោកហើយ បើសិនគេសួរលោកហើយ ខ្ញុំសូមអភ័យទោស។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកមានបានចាំថាធ្លាប់ឃើញមានគេមកថតកុន ថតអ្នកដែលសាងសង់ទំនប់១មកវានេះដែរឬទេ?

**ឆ៖** រឿងថតអីៗខ្ញុំបាទមិនដឹងទេ តែខ្ញុំបានដឹងថា មុន មានគេមកបើកការដ្ឋានដែលមានថា -- ឮសួរថា អ្នកធំអង្គការមកបើកការដ្ឋាន ហើយមានទាំងជនជាតិចិនមកផង គឺយើងដឹងបានតែប៉ុណ្ណឹងត្រង់មុខមាត់ ឬក៏ឃើញ គឺមិនឃើញទេ គ្រាន់តែដឹងឮប៉ុណ្ណឹង។

**ស៖** ដូច្នេះ រូបលោកផ្ទាល់ ថ្ងៃគេសម្ពោធនោះ លោកមិនមានវត្តមាននៅក្នុងពិធីសម្ពោធហ្នឹងទេអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** យើងនៅដូចគ្នា តែប្រជាជន យុវជនច្រើន យើងនៅឆ្ងាយចង់១គីឡូអីឯណោះ ស្តាប់តាមតែមីក្រូ មិនអាចឃើញមុខ ថាអ្នកណា ជាអ្នកណាទេ ថ្នាក់ដឹកនាំនោះ។

[១០:៤០:១៣]

**ស៖** លោកបាននិយាយអំពីអ្នកជំងឺ អ្នកដែលឈឺនៅលើការដ្ឋានគឺអ្នកនៅក្នុងក្រុមរបស់លោក

ក្នុងកងរបស់លោក។ អ៊ីចឹង លោកអាចរៀបរាប់អំពីរោគសញ្ញានៃជំងឺរបស់អ្នកជំងឺទាំងអស់នោះបានដែរឬទេ?

**ឆ៖** អ្នកជំងឺនៅក្នុងកង ឬក៏ក្រុមអ៊ីចឹងវាភាគច្រើនរាក រាករូស រាកហើម ដោយសារខ្វះជាតិផ្អែម ជាតិអំបិល វាតែប៉ុណ្ណឹង។ ភាគច្រើន គឺហើម។

**សៈ** ពេលលោកនិយាយអំពីថាហើមហ្នឹង ខ្ញុំចង់សួរលោកថា តើគាត់ហើមនៅត្រង់ណាលើរាងកាយគាត់ហ្នឹង គាត់ហើមនៅកន្លែងណាដែរ?

**ឆ៖** សំខាន់ យើងហូបមិនគ្រប់ ហើយយើងហើមគឺមើលទៅសាច់យើងរលោង យើងចុចៗទៅទ្រុឌ ភាគច្រើនគឺចុចដៃខ្លួនឯងហ្នឹងទៅឃើញហើយ។ បើថាស្គម វាអត់មានឈឺទេគ្រាន់តែស្គម។ បើថាហើម វារលោងអ៊ីចឹងទៅ ចុចទៅទ្រុឌនៅហ្នឹង ដឹងថាហើម។

**សៈ** តើលោកឃើញថាហើមហ្នឹង ហើមត្រង់កន្លែងណាដែរ លើខ្លួនគាត់នោះ? ហើយពេលដែលហើមហ្នឹង តើមានផលប៉ះពាល់អ្វីដែរផ្នែកសរីរាង្គកាយយើងហ្នឹង? តើធ្វើឲ្យយើងហ្នឹងក្លាយជាមនុស្សពិការ ឬធ្វើអីមិនកើត? អ៊ីចឹង ខ្ញុំចង់សួរលោកថា តើផលប៉ះពាល់នៃរោគហើមនេះមានអ្វីខ្លះ?

**ឆ៖** យើងខ្ញុំក៏ -- និយាយរួមក្នុងកងគ្មាននរណាគិតពីអ្នកណាទេ គឺរស់រៀងខ្លួន របបរៀងខ្លួនហូបមិនគ្រប់ ហើមទៅពេទ្យ។ មានពេទ្យប្រចាំវរៈ តែគ្មានថ្នាំអីឲ្យពិសេសនោះទេ។ យើងគ្មានថ្នាំ ឬក៏និយាយរួមគឺថ្នាំអាចម៍ទន្សាយតែម្តង លេបទៅ ប៉ុណ្ណឹង។

[១០:៤៣:២៤]

**សៈ** បាទ ខ្ញុំយល់អ្វីដែលលោកបានរៀបរាប់ហ្នឹងហើយ ក៏ប៉ុន្តែខ្ញុំមិនយល់ថា នៅតែមិនទាន់យល់ថា តើផលប៉ះពាល់នៃរោគហើមនេះ វាប៉ះពាល់កន្លែងណាខ្លះ? ប៉ះពាល់ត្រង់សន្លាក់ ហើយធ្វើឲ្យមនុស្សហ្នឹងបត់ដៃបត់ជើង លើកដៃលើកជើង គន្លាក់ដៃគន្លាក់ជើងហ្នឹងអត់បាន ឬក៏យ៉ាងណា? ខ្ញុំចង់ដឹងថា តើវាជះឥទ្ធិពលអីខ្លះលើការកម្រើកសរីរាង្គកាយយើងហ្នឹង ជាមនុស្សអ្នកដែលកើតជំងឺហ្នឹង?

**ឆ៖** និយាយរួម ហើមមកពីខ្វះអាហារហ្នឹង វាតែខ្វះញុយដង យូរខែទៅគឺហើម និយាយរួមវាខ្វះជាតិអាហារហ្នឹងគឺហើមហើយ រួចបើបានថ្នាំឬក៏គេបន្ថែមរបបអីតិចតួចដោយសារគេ ខាងសេដ្ឋកិច្ចគេចេះថែមថយ ឬក៏អី យើងអាចនិយាយរួម វាបាត់ហើម។ ព្រោះយើងហើម គ្រាន់តែយើងគ្នាយើងទេ ប៉ុន្តែយើងមិនមានសិទ្ធិថា “អឺ! ហើមយ៉ាងម៉េចយ៉ាងម៉ា?” យើងអត់ដឹងទេ។ យើងការពារតែខ្លួនយើង កុំឲ្យឈឺទៅ បាន។ យើងអត់មានសិទ្ធិទៅវិភាគអីអ៊ីចឹងៗអី អត់ទេ។

**សះ** តើអ្នកដែលមានជំងឺហើមហ្នឹង មានប្រហែលជាប៉ុន្មានភាគរយដែរធៀបទៅនឹងអ្នកដែលមិនឈឺ ឬធៀបទៅនឹងអ្នកដែលមានជំងឺផ្សេងទៀតហ្នឹង? អ៊ីចឹងខ្ញុំចង់ដឹងថា តើអ្នកធ្វើការទាំងអស់គ្នាសុទ្ធតែហើម ឬក៏គ្រាន់តែជាមនុស្សមួយចំនួនទេ អ្នកធ្វើការមួយចំនួនទេ ឬក៏អ្នកធ្វើការហ្នឹងតិចបំផុតដែលមានរោគហើមហ្នឹង?

**ឆះ** បើនិយាយតែនៅក្នុងកងគ្នា ៣០នាក់អ៊ីចឹង គឺ ពីរ បី ឬក៏បួននាក់ហ្នឹងអស់ហើយ ហើមដែលថាមានជំងឺផ្សំហ្នឹងខ្លួនឯងផង យើងអត់អាហារយូរផង បើនិយាយទូទៅ ខ្ញុំមិនច្បាស់ទេ។ បើក្នុងកងយើងអាចជួបគ្នារាល់ថ្ងៃ យើងមើលមុខដឹងថា "ហ្អ៎ក! ហើម" យើងអាចចែករំលែកអីតិចតួច ពេលបានរបបមកយើង -- ប៉ុន្តែអាហ្នឹងបានតែ១៧ ដូចគ្នាទេបានយើង អើមួយស្លាបព្រាពីរស្លាបព្រាថែមឲ្យអ្នកហើមអ៊ីចឹងទៅ ប៉ុណ្ណឹង។

[១០:៤៦:២៩]

**សះ** អ៊ីចឹងក្រៅពីរោគហើម រោគសញ្ញាហើមហ្នឹង លោកនិយាយអម្បាញ់មិញហ្នឹងពីរោគសញ្ញាផ្សេងទៀតដូចជា រោគរាកជាដើម រាករូសហ្នឹង។ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើបើតាមលោកដឹង មូលហេតុនៃការរាករូសហ្នឹង មកពីអ្វីដែរ?

**ឆះ** និយាយរួមគឺការហូបចុក មិនមានអនាម័យ ឃ្លានពេលណា យើង របស់អីដែលត្រូវហូបបាន យើងទៅបេះបោចមកហូបអ៊ីចឹងអាចប៉ះពាល់ជំងឺរាកហ្នឹង។ បាទ ហូបផ្ដេសផ្ដាស ស្លឹកឈើជាដើម មើម ផ្លែឆ្នោតទុំអ៊ីចឹងទៅ។ ប៉ុណ្ណឹងឯង។

**សះ** លោកក៏បាននិយាយផងដែរថាមានអ្នកធ្វើការហ្នឹងមានដំបៅ តើលោកមានបានកត់សម្គាល់ថាតើដំបៅហ្នឹងក្លាយដែរឬទេ? ហើយថាតើមានការព្យាបាល ឬក៏មានថ្នាំអ្វីអាចព្យាបាលដំបៅដែលក្លាយនេះដែរឬទេ?

**ឆះ** ថ្នាំដូចខ្ញុំនិយាយអ៊ីចឹង គឺមានតែថ្នាំអាចម៍ទន្សាយ ហើយនិង បេខ្វ បេស៊ីស ច្រកដប ចាក់ឲ្យប៉ុណ្ណឹង។

**សះ** ទឹកៗថ្នាំហ្នឹង លោកដឹងថាទឹកថ្នាំអ្វីដែរ? ហើយពេលគេឲ្យប្រើប្រាស់ហ្នឹងយ៉ាងម៉េចដែរគេឲ្យផឹក ឬក៏គេចាក់នឹងសេរ៉ាុំង?

**ឆះ** ថ្នាំបេខ្វ គឺគេចាក់ដៃ សាច់ដុំ។ បើថ្នាំគ្រាប់ៗ គេឲ្យយើងលេប។

**សះ** តើអ្នកណាជាអ្នកចាក់ថ្នាំហ្នឹង?

**ឆ៖** បាទហ្នឹងនៅក្នុងកង ឬវរៈ បើអ្នកណាឈឺធ្ងន់ គេបញ្ជូនទៅពេទ្យឃុំ ឬពេទ្យ គេហៅថា ទៅពេទ្យសង្កាត់ បើឈឺល្មមៗ ចាក់នៅក្នុងវរៈដែលមានពេទ្យប្រចាំវរៈចាក់ឲ្យ។

**ស៖** តើក្រុមពេទ្យចល័តហ្នឹង គេមកលើការដ្ឋានដើម្បីចាក់ថ្នាំតែម្តង ឬក៏យ៉ាងណា?

**ឆ៖** គឺគេនៅចាក់ប្រចាំការនៅឯរោងប្រចាំវរៈ គឺគេនៅតែនឹងរោង បើអ្នកណានៅ គេនឹងធ្វើការចាក់ថ្នាំ ឬរាយការណ៍ឲ្យប្រធានកងប្រធានវរៈហ្នឹងទៅ យើងអាចសុំគេចាក់ថ្នាំមួយឬក៏ពីរម្ហុលថ្នាំអីខ្លះ ជាក់ស្តែង ព្រោះថ្នាំ ខ្ញុំមើលទៅវាមានតែប៉ុណ្ណឹង។

[១០:៥១:១០]

**ស៖** តើលោកដឹងដែរឬទេ ថាកងចល័តហ្នឹងមានសម្ភារៈគ្រប់គ្រាន់ដើម្បីសម្លាប់មេរោគ សម្លាប់ -- ស្ងោរសម្លាប់សេរ៉ាំងអីជាដើមនោះ មុននឹងចាក់ថ្នាំដែរឬទេ?

**ឆ៖** មាន។

**ស៖** អ៊ីចឹងខ្ញុំសួរថាតើគាត់រម្ងាប់មេរោគ ឬក៏សម្លាប់មេរោគហ្នឹង គេធ្វើយ៉ាងដូចម្តេចដែរ?

**ឆ៖** គឺគាត់គ្រាន់តែស្ងោរសេរ៉ាំង និងម្ជុលហ្នឹងទៅ គឺជារៀងរាល់ពេលគឺស្ងោរប៉ុណ្ណឹងបាន។

**ស៖** បាទ លោកសាក្សី ខ្ញុំសូមអរគុណ។ ខ្ញុំអស់សំណួរហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីលោកសាក្សី! ខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់លោក។ នៅក្នុងចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត E3/5267 នៅត្រង់ទំព័រទី១ ERN ជាភាសាអង់គ្លេស 00282351, បារាំង 00482929, និងខ្មែរ 00271403។ លោកបាននិយាយថា នៅថ្ងៃរំដោះ១៩៧៥ លោកគឺជាសិស្សនៅវិទ្យាល័យទួលទំពូង។ តើត្រឹមត្រូវឬក៏អត់ទេ? ហើយបើសិនជាពេលនោះ លោក

នៅជាកូនសិស្ស តើលោកកំពុងតែរៀនសូត្រអំពីអ្វី?

**លោក អ៊ុត សេង៖**

**ឆ៖** នៅឆ្នាំ៧៥ គឺខ្ញុំជាសិស្សនៅលីសេទួលទំពូង ថ្នាក់ទី៣ក។ និយាយទៅថ្នាក់៣ទំនើបជាតិ។ ត្រង់ថាមេរៀនស្អី ខ្ញុំមិនចាំទេ គ្រាន់ថាគឺជាថ្នាក់ប្រឡងឌីប្លូមជំនាន់៧៥ ប៉ុន្តែយើងមិនទាន់បានប្រឡងផង វាដាច់១៧មេសា។

[១០:៥៤:២៥]

**ស៖** កាលដែលខ្ញុំសំណួរនេះ ដោយសារនៅត្រង់ទំព័រដដែលលោកបានប្រាប់ទៅអ្នកស៊ើបអង្កេតថានៅពេលមួយក្រោយក្លាយទៅ -- ១៩៧៩ ដែលលោកក្លាយទៅជាប្រធានមន្ទីរធនធានទឹក និងឧតុនិយមនៅខេត្តកំពង់ធំ តើលោកនៅចាំទេ ឬក៏ដឹងទេ ហេតុអ្វីបានក្លាយទៅជាមន្ត្រីធនធានទឹក និងឧតុនិយមនៅកំពង់ធំ? តើនេះដោយសារតែលោកមានការទទួលបានការអប់រំរៀនសូត្រមុនឆ្នាំ១៩៧៥ ឬ?

**ឆ៖** ៧៩ ឆ្នាំ៨០ ខ្ញុំបានចូលធ្វើការនៅរដ្ឋ នៅក្រសួង -- អ៎! នៅមន្ទីរកសិកម្មខេត្តកំពង់ធំ។ កាលនោះ ចំណេះដឹងដូចជាមិនទាន់មានគ្រប់គ្រាន់ទេ គ្រាន់តែថា កសិកម្មប្រាកដជាធ្វើស្រែហើយ យើងចូលទៅខាងធ្វើស្រែ ដឹងតែប៉ុណ្ណឹង។ ដល់ឆ្នាំក្រោយមក បានគេបែកបន្តិច បានជាក្រសួងធនធានទឹក។ ចំណេះដឹងទាំងឡាយ គឺបានក្រោយ៧៩ ដែលបានរៀនបន្តតិចតួច។

**ស៖** ហើយតើនៅឆ្នាំណាដែលលោកក្លាយទៅជាមន្ត្រីធនធានទឹក និងឧតុនិយមនៅខេត្តកំពង់ធំ?

**ឆ៖** នៅឆ្នាំ២០០០ រដ្ឋបានបង្កើតក្រសួងធនធានទឹក ហើយបានបំបែកចេញពីក្រសួងកសិកម្មមកជាក្រសួងធនធានទឹក និងឧតុនិយម នៅឆ្នាំ២០០០។

**ស៖** ខាងក្រោយបន្តិច នៅក្នុងចម្លើយដដែលហ្នឹង គឺអង់គ្លេស 00282354, បារាំង 0048 2932, ខ្មែរ 00271407។ លោកបានឆ្លើយដូចតទៅ៖ “សំណួរសួរថា តើលោកអាចប្រៀបធៀបទំនប់ក្នុងរបបចាស់និងរបបថ្មីបានទេ? ហើយពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩០ យើងនៅតែប្រើប្រាស់ទំនប់ចាស់របស់ ប៉ុល ពត ដដែល។ បន្ទាប់ពីឆ្នាំ១៩៩០ ទំនប់មានការខូចខាត បន្ទាប់មក ក្រសួងក៏ចាប់ផ្តើមធ្វើការជួសជុលឡើងវិញ។ ចាប់ពីឆ្នាំ២០០០ ទើបមានគម្រោងថ្មីត្រូវបានគេបង្កើតឡើង។ ខ្ញុំមានការចាប់អារម្មណ៍ទំនប់ចន្លោះពីឆ្នាំ១៩៧៩ ទៅដល់ ១៩៩០”។ តើប៉ុន្មានឆ្នាំហ្នឹង លោកអាចប្រាប់អំពីដំណើរការទំនប់ហ្នឹងបានទេ? តើទំនប់១មករា នៅចន្លោះឆ្នាំហ្នឹង ដំណើរការបានល្អទេ?

**ឆ៖** ទំនប់១មករា ឆ្នាំ១៩៧៩ ដាច់ គឺយើងនៅប្រើប្រាស់របស់ចាស់ដដែល គឺមានការខូចខាត

តិចតួច ដែលក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្មខេត្ត។ ការិយាល័យធារាសាស្ត្រខេត្តបានមកគ្រប់គ្រងនៅ១មករា។ នៅរហូតដល់ឆ្នាំ៩០ គឺនៅប្រើប្រាស់បាន បម្រើឲ្យពីរស្រុក – សន្ទុក និង បារាយណ៍។

[១០:៥៩:០៦]

**សៈ** តើទឹកហ្នឹង គេប្រើប្រាស់សម្រាប់ការស្រោចស្រពនៅក្នុងតំបន់ហ្នឹងឬ?

**ឆៈ** ខាងសន្ទុក គឺមានប្រឡាយបញ្ចេញមួយ ឬក៏ -- ដែលបង្ហូរជាអចិន្ត្រៃយ៍នៅរដូវវស្សាសម្រាប់ស្រោចស្រពកំពង់ថ្ម សំខាន់គឺឃុំកំពង់ថ្មទាំងមូល។ ហើយផ្នែកខាងទៅបារាយណ៍ គឺឃុំបល្ល័ង្ក។

**សៈ** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះ ថាតើក្រោយពេលដែលទំនប់ហ្នឹងគឺថាដំណើរការបាននោះ ផលិតផលដែលកសិករទទួលបាននៅក្នុងតំបន់ហ្នឹង គឺថាផលិត ទិន្នផលហ្នឹងវាកើនឬ?

**ឆៈ** ពី៧៩ ហៅថា យើងបើកទឹកអចិន្ត្រៃយ៍បម្រើឲ្យប្រជាជន ព្រោះកាលនោះមានប្រឡាយប្រព័ន្ធរបស់ -- គឺថាក្នុងរបបខ្មែរក្រហមហ្នឹងគេធ្វើឲ្យវាគួរសមដែរ អាចបង្ហូរ ឬក៏ទៅស្រែបានល្អ ហើយទិន្នផលក៏មិនជាខ្សោយដែរ គឺហៅថា ឧទាហរណ៍ថា ៣តោន គឺ៣តោន ឬក៏៣តោនចុះ ទៅតាមស្ថានភាពទឹកដែលហូរ ព្រោះភ្លឺស្រែនោះ វាអាចដាច់ប្រឡាយ វាអាចរាក់ទៅ វាបាន៦០, ៧០ភាគរយអ៊ីចឹងទៅ។

**សៈ** ហើយទិន្នផលបីតោនមួយហិកតានេះ ពីឆ្នាំ១៩៧៩, ៨០, ៨១ និងឆ្នាំបន្តបន្ទាប់ហ្នឹង គឺតើទឹកហ្នឹងវាអាចស្រោចស្រពទៅវាបានទិន្នផល ៣តោនក្នុង១ហិកតាទេ?

**ឆៈ** អានេះយើងមិនបានធ្វើ ហៅថាធ្វើតេស្តអីទេ គ្រាន់តែថា យើងមើលទៅតាមស្ថានភាពស្រូវដើមស្រូវ គឺថា៣តោន ឬក៏២តោនឡើងអ៊ីចឹងទៅ បើយើងមើល។ យើងគឺថាមិនបានតេស្តឲ្យបានត្រឹមត្រូវនោះទេ គ្រាន់តែថា យើងដាក់ស្តែងនឹងភ្នែក។

[១១:០២:៣៩]

**សៈ** បើខ្ញុំនិយាយយ៉ាងដូច្នេះ តើវាត្រឹមត្រូវដែរឬអត់ នៅឆ្នាំបន្តបន្ទាប់ពី១៩៧៩ ដល់ឆ្នាំ១៩៩០ថា ទំនប់១មករា ដំណើរការទៅបានល្អ ហើយទឹកហ្នឹងក៏ស្រោចស្រពទៅបានល្អ ហើយកសិករ គឺថាបានទទួលកសិផលពីការស្រោចស្រពនេះ។ បើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** គឺត្រឹមត្រូវ។

**សៈ** លោកទើបតែឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ គឺទំនប់៣០កញ្ញា ហើយ

យើងក៏ស្គាល់ទំនប់មួយទៀត គឺទំនប់៦មករា។ តើទំនប់ទាំងពីរនេះ ជាទំនប់ដាច់ដោយឡែកពីគ្នា ឬក៏ជាទំនប់តែមួយទេ?

**ឆ៖** ទំនប់ ១មករា និង ៦មករា គឺជាប់ខ្សែជាមួយគ្នា ដែលមានប្រវែងទាំងសងខាងបូកគ្នាហ្នឹង ៦០គីឡូម៉ែត្រ ហើយទំនប់ ៣០កញ្ញា វានៅក្នុងស្រុកមួយទៀត ជាប់ខេត្តសៀមរាប។

**ស៖** ខ្ញុំយល់ហើយ។ សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមត្រឡប់ទៅការងារនៅឯការដ្ឋានលើកទំនប់។ លោកបានឆ្លើយថា ខ្លួនលោកផ្ទាល់នេះ បានធ្វើការនៅទីនោះរយៈពេល៣ខែ នៅទំនប់១មករា នោះ។ តើការងារនេះ គឺថាសមាជិកដទៃទៀតនៃ -- សមាជិកដទៃទៀតនៅក្នុងកងរបស់លោកធ្វើដូចតែគ្នាទេឬ គឺសមាជិក៣១-៣២នាក់នៅក្នុងកងរបស់លោក គេធ្វើការនៅទំនប់ហ្នឹងអស់រយៈពេល៣ខែដូចលោកដែរឬក៏អត់ទេ?

**ឆ៖** ចំពោះរូបខ្ញុំផ្ទាល់អនុវត្តការងារនៅទីនោះបានរយៈពេលខ្លី ដោយសារប្រធានសហករណ៍បានទៅស្នើសុំវរៈដកខ្ញុំទៅភូមិ។ ការដកនេះ ខ្ញុំថា ខ្ញុំភ័យណាស់ តែដឹងធ្វើម៉េចបើគាត់មកដក ហើយយើងក៏ទៅតាមសំណូមពរប្រធានវរៈបានទៅដល់ភូមិវិញ ពុំបាននៅ១មករាជាប់លាប់ទេ។

[១១:០៥:៥៨]

**ស៖** ប្រសិនបើលោកមិនធ្វើការដល់រយៈពេល៣ខែទេ តើលោកអាចប៉ាន់ប្រមាណបានទេ លោកធ្វើការនៅទីនោះអស់រយៈពេលប្រហែលប៉ុន្មានសប្ដាហ៍នៅក្នុងពេលដែលលើកទំនប់ហ្នឹង សរុបទាំងអស់ទៅ អស់រយៈពេលប្រហែលជាប៉ុន្មានសប្ដាហ៍?

**ឆ៖** ពីនិយាយពីរឿងថ្ងៃដូចជា យើងអត់ដែលគិតថ្ងៃ បិទបើក១ ប៉ុន្តែគ្រាន់តែថារឿងយូរដែរនៅ១មករាហ្នឹង បើមិនគ្រប់៣ខែ ក៏ក្រោម៣ខែ ព្រោះយើងអត់មានពេលគិតថា ថ្ងៃទីប៉ុន្មានអី អត់ដឹងអីទាំងអស់ ដូចថាសុក្រ សៅរ៍ មួយ ពីរ អត់មាន អត់ដឹង ដឹងតែព្រឹកឡើងចប បង្គី ពលកម្ម។ ប៉ុណ្ណឹង។

**ស៖** អ៊ីចឹងលោកធ្វើការនៅទីនោះតែរយៈពេលបីបួនថ្ងៃ ឬក៏បីបួនសប្ដាហ៍នៅពេលដែលសមាជិកនៅក្នុងកងរបស់លោកទាំងអស់ហ្នឹងត្រឡប់មកភូមិវិញ?

**ឆ៖** កងគឺអត់មានទៅណាទេ គឺនៅតែក្នុងវរៈ នៅប្រចាំការអចិន្ត្រៃយ៍វរៈ រហូតទាល់ដាច់៧៩។ ពុំមានសិទ្ធិ មានយុវជនណាទៅណាបានទាំងអស់ គឺនៅការដ្ឋានទាំងអស់ លើកលែងមានការស្នើសុំពីសហករណ៍ គឺយើងបានទៅភូមិ។

**ស៖** ប៉ុន្តែអ្នកដែលនៅក្នុងកងរបស់លោក ៣១-៣២នាក់នៅ តើអ្នកទាំងអស់នោះបានធ្វើការ

អស់រយៈពេល៣ខែ នៅឯការដ្ឋានលើកទំនប់ដែរ ឬអត់? ហើយបើអត់ទេ ថាតើលោកបានចាកចេញមុនពួកគាត់ក្នុងរយៈពេលប៉ុន្មាន?

**ឆ៖** ក្នុងរយៈពេលក្រោយ ខ្ញុំថាក្រោយពីរបីខែហ្នឹង ក្រោយបន្តិចចុះ ហើយខ្ញុំបានចាកចេញមកភូមិ ហើយចាកចេញមកហើយ គឺចប់ហើយ យើងលែងដឹង លែងឮពីនៅវរៈ នៅកងហ្នឹងទៀតហើយ។ យើងមិនដឹងទេ។

**ស៖** នៅពេលដែលគេឲ្យលោកចាកចេញពីកង ហើយត្រឡប់ទៅភូមិវិញ តើលោកដឹងថាសមាជិកនៅក្នុងកងរបស់លោក ដឹងថាលោកទៅទីណាដែរទេ ឬក៏លោកមានបានប្រាប់អ្នកទាំងនោះថាលោកត្រូវបានគេឲ្យត្រឡប់ទៅភូមិវិញដែរឬទេ?

**ឆ៖** បើអ្នកជិតស្និទ្ធអ៊ីចឹង យើងអាចប្រាប់ថា "ប្រធានសហករណ៍បានដកខ្ញុំទៅវិញហើយ" ខ្ញុំថា -- ហើយយើងក៏ព្រួយបារម្ភ ប៉ុន្តែស្ងាត់ៗតែគ្នាឯងហ្នឹងទៅ។ ព្រួយត្រង់ថាគេដកទៅមិនដឹងយកទៅណា គ្រាន់តែប៉ុណ្ណឹងទេ អារម្មណ៍។

[១១:១០:២៥]

**ស៖** ប៉ុន្តែតើត្រឹមត្រូវដែរឬទេ ដែលថាលោកមានការព្រួយបារម្ភ -- តើត្រឹមត្រូវទេដែលថាសម្រាប់ខ្លួនគឺថា លោកគ្មានការព្រួយបារម្ភអ្វីទេក្នុងការត្រឡប់ឲ្យទៅភូមិវិញនោះ?

**ឆ៖** ការត្រឡប់ទៅភូមិ ការដកពីត្រង់ណាមួយ គឺព្រួយជានិច្ច។ មិនដឹងថាគេយកទៅណា ទៅធ្វើស្អី យើងអត់ដឹងទេ ទាល់តែទៅដល់គោលដៅបានដឹងថា លែងព្រួយ។

**ស៖** ខ្ញុំយល់ហើយ។ លោកបាននិយាយអំពីក្រុម មនុស្សមួយក្រុមប្រហែលជា៣៣នាក់ ដែលលោកក៏ជាសមាជិកនៅក្នុងក្រុមនេះដែរ ហើយកាលពីម្សិលមិញលោកក៏បាននិយាយអំពីក្រុមនេះ ថាជាផ្នែកមួយនៃក្រុមធំដែលមានមនុស្សដល់ទៅរាប់ពាន់នាក់។ ហើយនៅក្នុងចម្លើយរបស់លោក គឺលោកនិយាយថា មានប្រហែលជា៥០០ ទៅ ៦០០នាក់។ តើលោកអាចប៉ាន់ប្រមាណបានអំពីចំនួនសរុបនៃពលករនៅក្នុងកងធំនោះបានឬទេ តើវាមានតែត្រឹម៥០០-៦០០ នេះ ឬមានដល់រាប់ពាន់នាក់?

**ឆ៖** សម្រាប់វរៈទី២ យុវជនគឺប្រហែលជា ៥០០ ទៅ ៦០០នាក់ហ្នឹង គឺអស់ហើយ អត់មានលើសពីហ្នឹងទេ។

**ស៖** បើអ៊ីចឹង តើវាត្រឹមត្រូវដែរឬទេថា បើសិនណា ខ្ញុំនិយាយថាមានមនុស្សប្រហែលជា ៥០០-៦០០នាក់ ដែលត្រូវបែកចែកជាក្រុមតូចៗមានសមាជិក៣៣នាក់។ អ៊ីចឹងវាមានទាំងអស់ប្រហែល

ជា១៩ ទៅ ២០ក្រុម។ បើខ្ញុំធ្វើការគណនាបែបហ្នឹង តើវាត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** មិនដឹងដែរ គ្រាន់តែដឹងច្បាស់គឺយើងចាំតែកងយើងឲ្យច្បាស់ ប្រធានឈ្មោះអី ប៉ុណ្ណឹងគឺចប់។

**ស៖** ខ្ញុំយល់ហើយថា មេកងរបស់លោកឈ្មោះ ឡៃ គឺថាអ៊ីចឹងមានប្រធាន១៨-១៩នាក់ ដូចឡៃ ដែរ ដែលដឹកនាំក្រុមនីមួយៗ។ ត្រឹមត្រូវទេ?

**ឆ៖** ប្រហែលជាត្រឹមត្រូវហើយ ព្រោះគ្នាច្រើនណាស់ ហើយយើងសំខាន់ចាំមុនប្រធានកងយើងឲ្យច្បាស់ ខ្លាចមានបញ្ហាក្រោយ។

[១១:១៣:៥៦]

**ស៖** ហើយថាតើត្រឹមត្រូវដែរទេ ពាក់ព័ន្ធទៅនឹងទិន្នផល គឺថាក្រុមរបស់លោកត្រូវធ្វើការតែជាមួយ ឡៃ ហើយមានតែ ឡៃ ទេដែលត្រូវផ្តល់នូវការណែនាំអ្វីមួយទៅដល់ក្រុមរបស់លោក។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយសមាជិកទាំង៣៣នាក់នៅក្នុងក្រុម កងរបស់លោក តើគេមកពីភូមិជាមួយលោកតែមួយទេ ឬក៏គេមកពីភូមិផ្សេងៗដែរ?

**ឆ៖** គឺចម្រុះភូមិ។

**ស៖** តើលោកអាចប្រាប់ពីចំនួនភាគរយនៃក្រុមដែលមាន -- របស់លោកដែលមានចំនួន៣៣នាក់ហ្នឹង ប៉ុន្មានភាគរយជាប្រជាជនចាស់ ហើយប៉ុន្មានភាគរយជាប្រជាជនថ្មី?

**ឆ៖** យើងអត់ដឹងៗ ថាចាស់ ឬថ្មី។ យ៉ាងច្រើនយើងដឹងម្នាក់ ឬក៏ពីរនាក់ដែលស្និទ្ធស្នាលជាមួយគ្នា ព្រោះយើងអត់បានសួរថា "អេហ្អែងចាស់ ឬក៏ថ្មី" អីអត់ទេ អត់បាន។

**ស៖** ពេលលោកនិយាយតែមនុស្សមួយចំនួនតូចនេះ គឺថា -- មួយក្តាប់តូចនេះ តើលោកចង់និយាយប្រាំ ប្រាំមួយនាក់ ឬក៏១០នាក់?

**ឆ៖** សួរម្តងទៀត។

[១១:១៦:០៩]

**ស៖** លោកនិយាយថានៅក្នុងក្រុមរបស់លោកចំនួន៣៣នាក់នោះ គឺថាតែមានមនុស្សមួយចំនួនតូចដែលលោកបានស្គាល់ច្បាស់ គឺ -- តើលោកចង់និយាយថា ប្រាំ ប្រាំមួយនាក់ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ វាពិតមែន។

**ស៖** លោកចាំឈ្មោះមនុស្សបី បួន ឬក៏ប្រាំនាក់ដែលលោកស្គាល់ជិតដិតនេះដែរទេ?

**ឆ៖** នៅចាំ។

**ស៖** តើលោកអាចរៀបរាប់ឈ្មោះអ្នកទាំងនោះបានទេ?

**ឆ៖** ចាំតែឈ្មោះ មិនចាំត្រកូលទេ។ កាលនោះយើងស្គាល់តែឈ្មោះគ្នា មាន មិត្តវ៉ន មិត្តជឿន មិត្តណី មិត្តឈិន ហើយនិង រិន ប៉ុន្តែពីរនាក់ហ្នឹងបានស្លាប់ដោយសារជំងឺបាត់ហើយ។

**ស៖** ដូច្នេះ មនុស្សបួន ប្រាំនាក់ដែលលោកជិតដិតជាមួយនេះ តើលោកដឹងថាពួកគាត់ជាប្រជាជនចាស់ ឬក៏ជាប្រជាជនថ្មី? គឺមនុស្សប្រាំនាក់ដែលលោកទើបតែនិយាយអម្បាញ់មិញនេះ។

**ឆ៖** គឺប្រជាជន១៧មេសា។ យើងមិនអាចរាប់អានបានទេ អ្នកមូលដ្ឋាន ព្រោះយើងខ្លាច។

**ស៖** ចុះមនុស្ស២៨នាក់ទៀតនៅក្នុងក្រុមរបស់លោក ដែល -- ខ្ញុំគិតថាលោកមិនជិតស្និទ្ធជាមួយទេ តើលោកអាចប្រាប់បានទេ ថា២៨នាក់ផ្សេងទៀត ជាប្រជាជនចាស់ ឬប្រជាជនថ្មី?

**ឆ៖** បើតាមការស្មាន យើងមិនអាចដឹងថាអ្នកនោះចាស់ ឬថ្មីទេ បើយើងមិនបានស្និទ្ធស្នាលជាមួយគ្នា គឺៗយើងមិនអាចស្មានបាន ប៉ុន្តែយើងអាចមើលតាមសម្លៀកបំពាក់ បើសម្លៀកបំពាក់ចាស់ៗរហែក ប្រាកដជា១៧មេសា ហើយ គឺចាំ និងមើលចំណាំបានប៉ុណ្ណឹង។

[១១:១៩:៤៩]

**ស៖** ក្រុមរបស់លោកដែលមានមនុស្ស៣៣នាក់នោះ តើម្នាក់ៗដែលទៅធ្វើការនៅទំនប់១មករាហ្នឹងទទួលបានរបបអាហារដូចៗគ្នា ឬក៏ម្នាក់ៗទទួលបានរបបអាហារផ្សេងៗគ្នាដូចជាបបរជាដើម?

**ឆ៖** ពេលសម្រាកមកដល់រោងបាយ កន្លែងរោងបាយរួមហ្នឹងគឺយើងម្ចាស់ការរៀងខ្លួន គឺថាមានប្រដាប់ដាក់បបរមានកាម៉ែល ឬក៏ចានអ៊ីចឹងទៅ កំសៀវអ៊ីចឹងទៅ។ ទៅកន្លែងសេដ្ឋកិច្ចហ្នឹងទៅគេដួសដាក់ឲ្យយើងហើយ។ គេគ្រាន់តែថា គេដឹងថាអ្នកចាស់អ្នកថ្មីរបៀបម៉េច គឺគេអ្នក -- រួចយើងចាំតែយកមក ឲ្យប៉ុន្មាន គឺចប់ដើរចេញ។

**ស៖** ដោយសារតែវាមានមនុស្សរហូតទៅ ៥-៦០០នាក់ តើចុងភៅហ្នឹងអាចស្គាល់ថាអ្នកណាជាប្រជាជនចាស់ អ្នកណាជាប្រជាជនថ្មីដែរឬទេ? ហើយបើសិនជាឆ្លើយថាអាចហ្នឹង តើគេអាចសម្គាល់បានដោយរបៀបណា?

**ឆ៖** បើតាមយល់ទៅ គេចំណាំដូចថា សម្លៀកបំពាក់តែយូរបន្តិច គឺរហែក ប៉ះឡើងធ្ងន់ ពេល

ខ្លះដាច់ត្រឹមស្មាអ៊ីចឹងទៅ។ តែបើថ្មី --អ៎ន៎ែ! គេប្រជាជនមូលដ្ឋាន គឺគេមានតែសមរម្យរហូត។ គឺគេចំណាំតាមបែបហ្នឹង។

**ស៖** ខ្ញុំយល់ហើយគឺអ្វីដែលលោកបានគិតនៅពេលនោះថា ប្រជាជនគេបែងចែកយ៉ាងដូច្នេះឯង ប៉ុន្តែសំណួរខ្ញុំវិញ គឺសួរថា តើអ្នកដែលធ្វើការនៅរោងបាយនោះអាចកត់សម្គាល់ថាអ្នកណាជាប្រជាជនថ្មី ហើយនិងថាអ្នកណាជាប្រជាជនចាស់ហ្នឹងបានដោយរបៀបណា? លោកដឹងទេ?

**ឆ៖** ដូចខ្ញុំជម្រាបជូន គឺដោយសារសម្លៀកបំពាក់ ហើយបើប្រជាជនមូលដ្ឋានគេរាងហំហានថ្មី។ ពិសេសគឺគេ មានមួកកាតឹបពាក់។ បើប្រជាជន១៧ ច្រើនតែមួកស្លឹកត្នោត ឬក៏ជួតក្បាលក្រមាចាស់រហែកអ៊ីចឹងទៅ ប៉ុណ្ណឹង។

[១១:២៣:២២]

**ស៖** ខ្ញុំសុំសួរឲ្យបានច្បាស់លាស់ តើលោកដែលឃើញអ្នកធ្វើការនៅផ្ទះបាយហ្នឹង ឲ្យរបបអាហារតិចទៅឲ្យមនុស្សខ្លះ និងឲ្យច្រើនទៅឲ្យមនុស្សខ្លះដោយគេសម្គាល់ទៅលើការស្លៀកពាក់ខោអាវ និងពាក់មួកកាតឹប ដូចលោកថាហ្នឹងដែរទេ?

**ឆ៖** កន្លែងចាំដួស ចាំចែកបបរហ្នឹង គឺវាត្រូវការយូរ យើងរង់ចាំដាក់កាម៉ែលហ្នឹងអ៊ីចឹងទៅ អ្នកជិត អ្នក -- យើងនៅជាមួយគ្នាយូរយើងដឹងថា ហើយនិងសំអាងលើសម្លៀកបំពាក់ មួកកាតឹប អាវក្រមា ព្រៃឈរអីអ៊ីចឹងទៅ។ បើ១៧ ស្រួលចំណាំបំផុតហើយ ហើយប្រដាប់បបរហ្នឹងក៏មិនល្អដូចខាងគេនោះទេ។ គឺយើង សំខាន់ យើងមិនបានឈរវិភាគឲ្យយូរទេ គ្រាន់តែថាបានបបរយើងដើរចេញ ទើសគេ។

**ស៖** ខ្ញុំសុំសួរតាមរបៀបផ្សេងទៅវិញ។ តើលោកដែលធ្លាប់ឮសូរគេនិយាយ ឬគេណែនាំតាមមីក្រូទៅប្រាប់ចុងភៅថាឲ្យផ្តល់របបអាហារហ្នឹងឲ្យប្រជាជនមូលដ្ឋានហ្នឹងច្រើនជាងប្រជាជនថ្មីដែរឬទេ ធ្លាប់ដែរឮគេនិយាយអ៊ីចឹងតាមមីក្រូទេ?

**ឆ៖** អត់ដែលមានទេ។

[១១:២៥:១៩]

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទ ស្តីអំពីកងពិសេសសម្រាប់មនុស្សខ្ចិល។ តើលោកដឹងថាសមាជិកណាម្នាក់នៅក្នុងក្រុមរបស់លោកដែលមានចំនួន ៣២នាក់ហ្នឹង ដែលត្រូវបានគេដកយកទៅដាក់បញ្ចូលក្នុងកងពិសេសសម្រាប់មនុស្សខ្ចិលនេះដែរទេ?

**ឆ៖** ពុំមានដែលដកទេកងហ្នឹង គេអត់។

**ស៖** តើកងពិសេសសម្រាប់មនុស្សខ្ជិលនេះ បានចាប់ដំណើរការនៅពេលណា? តើមួយរយៈក្រោយមក ពីរបីសប្តាហ៍ក្រោយមក ឬក៏ថាកងនេះគេបានបង្កើតឡើងដាក់ឲ្យដំណើរការតាំងពីពេលលោកទៅដល់នៅឯការដ្ឋាននោះ?

**ឆ៖** មិនដឹងគេបង្កើតពីអង្កាល់ទេ យើងមិនដឹងទេរឿងហ្នឹង គ្រាន់តែថាក្រោយមកយើងឃើញការថា "ហ្ន៎! កងពិសេស" ប៉ុណ្ណឹងឯង។

**ស៖** តើលោកបានឃើញ កងៗនេះនៅក្នុងរយៈពេល៣ខែដែលលោកស្ថិតៗនៅទីនោះ នៅពាក់កណ្តាលរយៈពេលដែលលោកបានធ្វើការនៅពេលនោះហើយ ឬក៏នៅពេលណា សូមលោកបញ្ជាក់ពេលវេលាឲ្យបានច្បាស់លាស់បន្តិច?

**ឆ៖** អត់ៗៗៗយល់ សូមម្តងទៀត។

[១១:២៧:៣៥]

**ស៖** លោកមិនដឹងបានច្បាស់លាស់ទេថា កងពិសេសនេះចាប់ដំណើរការនៅពេលណាទេ។ សំណួររបស់ខ្ញុំ គេបង្កើតកងនេះដល់ពេលចុងក្រោយលោកជិតឈប់ធ្វើការនៅទីនោះ ឬក៏ពេលដែលលោកបានទៅដល់នោះនៅពាក់កណ្តាលទី? ដូច្នេះសំណួរសួរថា តើលោកបានឃើញកងពិសេសសម្រាប់មនុស្សខ្ជិលនេះ នៅពេលណា?

**ឆ៖** កងពិសេសនេះ ទំនងទើបតែនឹងកើតដែលមានអ្នកខ្ជិលច្រអូស ដោយសារចង់ព្រមានដល់ក្រុមដទៃអ៊ីចឹង កើតជាមួយគ្នាអ៊ីចឹងតាមមើលទៅ មិនច្បាស់ទេតែគ្រាន់ថា ដល់ស្រាប់តែឃើញទៅធ្វើការជួបគ្នាគេតម្រង់ជួរ ថានោះកងពិសេស គឺតែប៉ុណ្ណឹងឯង។

**ស៖** ខ្ញុំយល់ចម្លើយរបស់លោកហើយ ប៉ុន្តែលោកប្រើពាក្យថា "ប្រហែល"។ គឺប្រហែលជាលោកស្មានហើយ អ៊ីចឹងឯងបានជាខ្ញុំសូមសួរឲ្យលោកបញ្ជាក់ឲ្យបានច្បាស់លាស់ថា កងពិសេសសម្រាប់មនុស្សខ្ជិលនេះ ត្រូវបានបង្កើតឡើងនៅពេលណាដែរ?

**ឆ៖** យើងពុំដឹងថាគេបង្កើតហ្នឹងពីពេលណាទេ យើងនៅកងផ្សេង ប្រឹងតែការងារកងខ្លួនឯង។

[១១:២៨:២៧]

**ស៖** តើលោកដឹងថាកងមួយនេះមានសមាជិកតែប្រហែលជា ២០នាក់ទេ ឬក៏កងពិសេសមួយនេះ ពីដើមទីមកគឺថាមានសមាជិកតិចតួច ហើយក្រោយមកបានមានច្រើន?

**ឆ៖** ដូចនិយាយអ៊ីចឹងថា ពីដើមវាតិចតួច តែមនុស្សវាកាន់តែហេវហត់ច្រើន កាន់តែប្រមូលបានពី ១០ ទៅ ២០, ពី២០ឡើង ចេះតែហូរ បញ្ចូលទៅហូរហែ តាមនារី តាមយុវជនអ៊ីចឹងទៅ។

**ស៖** លោកបានឆ្លើយថា លោកមានភាពជិតស្និទ្ធជាមួយមនុស្សតែប្រហែលជាប្រាំទៅប្រាំមួយនាក់ទេនៅក្នុងកងរបស់លោក ក្រៅពីនោះលោកមិនប៊ាននិយាយជាមួយទេ។ តើត្រឹមត្រូវដែរឬទេថាលោកក៏មិនបាននិយាយទៅកាន់សមាជិកនៅក្នុងកងដទៃទៀតដែលធ្វើការនៅឯទំនប់នោះដែរ? តើអ៊ីចឹងឬក៏អត់ទេ?

**ឆ៖** ពិតជាត្រឹមត្រូវ។ មួយថ្ងៃយើងនិយាយឲ្យបានតែពីរម៉ាត់ ឬបីម៉ាត់ទេ កុំនិយាយល្អ គឺសុខសប្បាយ។

**ស៖** តើធ្វើដូចម្ដេចដែលលោកដឹងថាប្រជាជនដែលគេយកទៅដាក់កងពិសេស គឺដោយសារតែអ្នកទាំងនោះជាមនុស្សខ្ជិល? តើលោកដឹងថាគេជាមនុស្សខ្ជិលហ្នឹង លោកដឹងមកពីប្រភពណាដែរ?

**ឆ៖** គឺប្រធានកង ពេលល្ងាចម៉ោងចប់ការងារ គឺគេប្រជុំអ៊ីចឹងទៅ គេប្រាប់ គេលើកឡើងគេដាស់តឿនឡើង គេបង្ហាញឡើងពីមនុស្សដែលនៅកងពិសេស ដោយសារប្រធានកងហ្នឹងឯង។

[១១:៣២:០៤]

**ស៖** តើមេកងរបស់លោកដែលប្រាប់ថាមនុស្សខ្ជិលៗហ្នឹងត្រូវតែនៅក្នុងពិសេសរយៈពេលប៉ុន្មានទេ ពីរបីថ្ងៃ ពីរបីសប្ដាហ៍ ឬក៏ត្រូវទៅនៅកងរយៈពេលប៉ុន្មានដែរ?

**ឆ៖** ក្រុមពិសេសគឺក្រុមពិសេស គឺនៅចប់មួយការដ្ឋាន ឬក៏បន្តមកនៅក្នុងសង្កាត់ក៏អាចមាន។ ប៉ុន្តែកន្លងមក ខ្ញុំចេញមុនមក គឺមុនចប់ការដ្ឋាន ប៉ុន្តែពួកហ្នឹងគឺនៅតែជាកងពិសេសដដែល។

**ស៖** លោកសាក្សី សូមឆ្លើយមកសំណួរខ្ញុំតែអ្វីដែលលោកបានដឹងបានហើយ។ តែសំណួររបស់ខ្ញុំសួរថាតើលោកបានដឹងទេ ថាប្រជាជនគេយកទៅដាក់កងពិសេសសម្រាប់មនុស្សខ្ជិលហ្នឹងតែក្នុងរយៈពេលបីថ្ងៃ តែមួយថ្ងៃ ពីរបីសប្ដាហ៍ ឬក៏គេយកទៅដាក់ក្នុងកងពិសេសសម្រាប់មនុស្សខ្ជិលនេះជារៀងរហូត?

**ឆ៖** នៅរយៈពេលធ្វើការ គេឃើញកងពិសេសជាប្រចាំ។ ក្នុងការរំសាយ ឬក៏យ៉ាងណាមិនដឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំឃើញនាឡិកាដល់ម៉ោង ប៉ុន្តែសូមសួរសំណួរចុងក្រោយ។

**សួរដោយលោក វិុចទ័រ កូប៉េ៖**

**ស៖** តើការគណនារបស់ខ្ញុំត្រឹមត្រូវទេ ដែលខ្ញុំនិយាយថាពលករប្រហែល៦០០នាក់ ហើយនៅក្នុងកងពិសេសមនុស្សខ្មិលនេះមានប្រហែលតែ២០នាក់។ ហ្នឹងបើគិតទៅគឺវាមានតែពីរបីភាគរយតែប៉ុណ្ណោះ បើយកចំនួនមនុស្សខ្មិលនៅក្នុងកងពិសេសនេះទៅប្រៀបធៀបជាមួយនឹងមនុស្សសរុប។ តើត្រឹមត្រូវទេ?

**លោក អ៊ិត សេង៖**

**ឆ៖** ត្រឹមត្រូវ។

**លោក វិុចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលសវនាការនៅក្នុងបន្ទប់សវនាការនេះវិញឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥នាទី ដល់ម៉ោង ១៣:៣០នាទី)*

[១៣:៣១:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីទាំងអស់នៃរឿងក្តីនេះថា នៅក្នុងកិច្ចដំណើរការសវនាការនៅរសៀលនេះ ដោយចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិ អវត្តមាន ដោយមូលហេតុគាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន គាត់មិនអាចចូលរួមក្នុងកិច្ចដំណើរការសវនាការនេះបាន។ បន្ទាប់ពីយើងខ្ញុំពិភាក្សាពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងភាគីជាតិ ជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមាននៅរសៀលនេះ។ ហើយការសម្រេចនេះ ផ្អែកលើបទប្បញ្ញត្តិនៃវិធាន ៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដើម្បីការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

ជម្រាបសួរលោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនទៀតទៅកាន់រូបលោក។ មុនពេលឈប់សម្រាកបាយថ្ងៃត្រង់ ខ្ញុំបានសួរលោកអំពីកងពិសេសសម្រាប់ក្រុមមនុស្សខ្ជិល។ ហើយពីខាងដើមនោះ លោកក៏បានផ្តល់សក្ខីកម្មថា លោកគិតថាប្រជាជននៅក្នុងកងរបស់លោកភាគច្រើននោះ គឺជាប្រជាជនមូលដ្ឋាន។ តើលោកឆ្លើយបែបនេះមែនទេ? ហើយបើយ៉ាងដូច្នោះ ធ្វើម៉េចទើបបានដឹងថាមនុស្សភាគច្រើននៅក្នុងកងរបស់លោកហ្នឹង គឺជាប្រជាជនមូលដ្ឋាន?

**លោក អ៊ុត សេង៖**

**ឆ៖** អានេះ តាមការសង្កេតរបស់ខ្ញុំ ហើយធ្លាប់នៅក្នុងកងជាមួយគ្នា យើងដឹងពី -- ដូចខ្ញុំនិយាយដដែល គឺសម្លៀកបំពាក់ផ្ទាល់ខ្លួន។ យើងអាចដឹងថា អ្នក១៧ ឬក៏អ្នកមូលដ្ឋាន។

[១៣:៣៤:៥៤]

**ស៖** ដូច្នេះ យោងទៅតាមសម្លៀកបំពាក់ដែលមនុស្សនៅក្នុងកងរបស់លោកស្លៀកពាក់ហ្នឹង គឺធ្វើឲ្យលោកកត់សម្គាល់ឃើញថា មនុស្សភាគច្រើននៅក្នុងកងរបស់លោកហ្នឹង គឺជាប្រជាជនមូលដ្ឋាន តើអ៊ីចឹងមែនទេ?

**ឆ៖** ប្រាកដមែន។

**ស៖** តើលោកចាំឈ្មោះមេកងមួយនេះដែរទេ គឺកងពិសេសសម្រាប់ក្រុមមនុស្សខ្ជិលនេះ?

**ឆ៖** មិនស្គាល់ឈ្មោះ តែស្គាល់មុខ។

**ស៖** តើលោកនៅចាំ ឬក៏លោកដឹងថា មេកងហ្នឹង រាយការណ៍ទៅអ្នកណា? តើថ្នាក់លើផ្ទាល់របស់មេកងហ្នឹងជាអ្នកណា លោកដឹងទេ?

**ឆ៖** ខ្ញុំបាទមិនដឹងទេទាន។

[១៣:៣៦:២៣]

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅនិយាយអំពីថា ពលករប្រហែលជា៩០ភាគរយ គឺមិនចាត់ទុកថាជាអ្នកខ្ជិលទេ គឺខ្ញុំចង់និយាយពលករដែលធ្វើការនៅការដ្ឋានលើកទំនប់។ យើងខ្ញុំបានស្ដាប់នូវខ្សែអាត់វីដេអូកិច្ចសម្ភាសន៍របស់លោក លោកនិយាយនៅត្រង់ចំណុចមួយថា ប្រសិនបើ -- ទោះបីជាក្រុមរបស់លោកបញ្ចប់ការងារ ឬក៏មិនបានបញ្ចប់ការងារក៏ដោយ គឺលោកត្រូវបន្តធ្វើការងារនៅថ្ងៃបន្តបន្ទាប់តទៅទៀត ហើយក្រុមរបស់លោកមិនត្រូវបានបង្ខំឲ្យធ្វើការអ្វីពិបាកទេ។ តើលោកនៅចាំថាលោកបាននិយាយត្រង់ចំណុចមួយនេះជាមួយអ្នកស៊ើបអង្កេតដែរឬទេ?

**ឆ៖** ដូចជាចាំបាន នៅពេលនោះ ខ្ញុំនិយាយអ៊ីចឹងមែន។

**ស៖** ហើយយើងខ្ញុំក៏បានឮលោកនិយាយថា ដោយសារតែក្រុមរបស់លោកមិនមែនជាអ្នកខ្ជិល គឺដូច្នេះនៅក្នុងក្រុមរបស់លោក ក៏ដូចជារូបលោកគឺថាមិនមានបញ្ហាអ្វីទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតមែន គ្មានបញ្ហា។

**ស៖** ដូច្នេះ ខ្ញុំអាចសន្និដ្ឋានបានថា ពលករ៩៧ភាគរយនៅក្នុងក្រុមរបស់លោក ដែលធ្វើនៅការដ្ឋានលើកទំនប់ហ្នឹង គឺថាមិនមែនជា គេមិនចាត់ទុកជាអ្នកខ្ជិលទេ ហើយមិនមានបញ្ហាអ្វីទេ មែនទេ?

**ឆ៖** ប្រាកដមែន វាគ្មានបញ្ហាអីនឹងកើតឡើង។

[១៣:៣៨:៤៥]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរអំពីពេលម៉ោងការងារ ដោយសារតែមានអ្នកខ្លះ ហើយមានសាក្សីម្នាក់បានបញ្ជាក់ថា ពេលសម្រាកបាយថ្ងៃត្រង់អាចពីម៉ោងមួយ ទៅដល់ម៉ោងពីរ ឬក៏ -- ពីម៉ោងដប់មួយ ដល់ម៉ោងពីរ ឬពីម៉ោងមួយ ទៅដល់ម៉ោងពីរ។ តើចម្លើយរបស់សាក្សីដែលឆ្លើយបែបនេះត្រឹមត្រូវទេ?

**ឆ៖** ពីម៉ោង -- គឺសម្រាកពីម៉ោងដប់មួយកន្លះទៅ គឺយើងទៅ ទៅហូបបាយ។ ម៉ោងមួយកន្លះគេចាប់ផ្ដើមបន្ត។

**ស៖** សាក្សីមួយចំនួនដែលបានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះកាលពីសប្ដាហ៍មុនក៏បានឆ្លើយថាមានពេលសម្រាកនៅពាក់កណ្ដាលពេលព្រឹក គឺពីព្រឹក មកដល់ពេលបាយថ្ងៃត្រង់ ចន្លោះពាក់កណ្ដាលពេលហ្នឹង គឺមានការអនុញ្ញាតឲ្យឈប់សម្រាកពេលហ្នឹង តើចម្លើយរបស់សាក្សីទាំងនោះត្រឹមត្រូវទេ?

**ឆ៖** ពិតជាត្រឹមត្រូវ ព្រោះមានសម្រាក គេហៅសម្រាកតូច មួយភ្លែត ចន្លោះម៉ោងហ្នឹង។

**ស៖** សាក្សីខ្លះក៏បានឆ្លើយថា បានធ្វើការនៅពេលយប់ ហើយការងារនៅពេលយប់នេះ គឺធ្វើតែនៅពេលខ្លះទេ។ ហើយសាក្សីខ្លះឆ្លើយថា ការធ្វើការងារនៅពេលយប់ហ្នឹង តែនៅខែភ្លឺទេ គឺប្រហែលជាធ្វើម្ដងៗ ម្ដងក្នុងខែទេ។ អ៊ីចឹងតាមការចងចាំរបស់ -- តើលោកនៅចាំថាមានធ្វើការនៅពេលយប់ដែរទេ?

**ឆ៖** ការងារនៅពេលយប់ប្រាកដជាមាន ប៉ុន្តែដូចខ្ញុំនិយាយអ៊ីចឹង ពី -- មានករណីពិសេសអាហ្នឹងគេបើកភ្លើង។

[១៣:៤១:៣៤]

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ករណីពិសេសហ្នឹងកើតមាននៅពេលណា? តើកាលៈទេសៈបែបណាដែលចាត់ទុកថាវាជាករណីពិសេសនាំឲ្យពលករហ្នឹងធ្វើការនៅពេលយប់?

**ឆ៖** យើងមិនអាចដឹងថា ករណីហ្នឹងបែបណាទេ។

**ស៖** សូមអរគុណ។ លោកចាំថាធ្លាប់បានឃើញមានឧបករណ៍ធុនធ្ងន់ដូចជាឡានអាប៊ុលដូហ្សឺរ ឡានឈូសដីហ្នឹង គឺថាឈូសៗឆាយដីនៅការដ្ឋាននោះដែរទេ?

**ឆ៖** មិនៗធ្លាប់ឃើញ តែដាច់៧៩ ខ្ញុំបានឃើញគ្រឿងចក្រនៅក្នុងព្រៃឯទំនប់៦មករា។ មានអាប៊ុល មានគ្រឿងចក្រ ម៉ាស៊ីនដេសេតអីៗហ្នឹង។

**ស៖** តាមការចងចាំរបស់លោក តើប៊ុលដូហ្សឺរ និងឧបករណ៍ធុនធ្ងន់ដទៃទៀតដែលទុកចោល

នៅទីនោះដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ ឬក៏អត់ទេ?

**ឆ៖** ដោយអាជ្ញាកម្ពុជាប្រជាធិបតេយ្យទុកចោល រត់ចោល ដាច់៧៩ហ្នឹងទៅ គឺទុកចោល។

**ស៖** ហើយតាមការចងចាំរបស់លោក តើឧបករណ៍ធុនធ្ងន់ទាំងអស់ហ្នឹង គឺជាឧបករណ៍ប្រភេទអ្វីដែរ ជាឡានអាប៉ុលដូហ្សើរ ឡានឈូសឆាយដី ឬក៏ជាឧបករណ៍អ្វីខ្លះទៀតដែរ?

**ឆ៖** មាន ស្គាល់ៗខ្លាំងតែអាប៉ុល ហើយនិងឈូសថ្នល់ៗមានប៉ែលពីក្រោម ហើយនិងរោងជាងដែក ជាងអីនៅកន្លែងគ្រឿងចក្រហ្នឹង។

**ស៖** នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់១មករា តើលោកធ្លាប់បានឃើញដីបាក់ -- ធ្លាប់បានឃើញដីហ្នឹងវាបាក់គ្របសង្កត់ទៅលើពលករដែរទេ?

**ឆ៖** មិនដែលឃើញទេ ប៉ុន្តែធ្លាប់ឮនៅកន្លែងផ្សេង គេថា “អូ៎! ដីបាក់” ដល់សួរទៅថា កន្លែងធ្វើសំណង់ធំនោះ ជីករណ្ដៅគ្រឹះជ្រៅពេកទៅ គឺបាក់ ថាស្លាប់ ឬក៏រស់ប៉ុន្មាន គឺខ្ញុំមិនដឹងទេ។

[១៣:៤៦:០០]

**ស៖** នៅពេលដែលលោកធ្វើការនៅទីនេះ តើលោកធ្លាប់មានបទពិសោធន៍ជួបប្រទះការប្រើៗជាតិផ្ទុះដើម្បីកម្ទេចថ្មដែរឬទេ?

**ឆ៖** ពុំដែលមានប្រើជាតិផ្ទុះ។

**ស៖** ត្រឡប់មកនិយាយអំពីស្ថានភាពចំណីអាហារសម្រាប់កងរបស់លោកដែលធ្វើការនៅការ-ដ្ឋាននោះវិញ លោកដឹងថាអ្នកណាទទួលខុសត្រូវក្នុងការយកចំណីអាហារមកចែកជូន អ្នកណាទទួលខុសត្រូវខាងផ្នែកព័ស្តុភារ ខាងផ្នែកដឹកជញ្ជូនចំណីអាហារយកមកឲ្យពលកម្មនៅឯទំនប់នុ៎ង?

**ឆ៖** រឿងម្ហូប ឬរឿងជីវភាពបបរអីនុ៎ង គឺយើងដើរមកហូបនៅកន្លែងរោងវិញ។ មិនមានពីណាដឹកនាំយកទៅឲ្យដល់កន្លែងទេ ព្រោះរោងយើងនៅប្រហែល១គីឡូពីគ្នា។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែតើលោកដឹងអ្នកណាជាអ្នកយកចំណីអាហារមកកន្លែងហូបបាយហ្នឹង តើម្ហូបហ្នឹងវាបានមកដល់កន្លែងគេហូបបាយហ្នឹងដោយរបៀបណា? អ្នកណាដែលទទួលខុសត្រូវក្នុងការដឹកជញ្ជូននុ៎ង?

**ឆ៖** អត់មានដឹងជញ្ជូនទេ យើងចូលកន្លែងចុងភៅហ្នឹងទៅ យើងកាន់តែកាម៉ែលមួយទៅគេនឹងវាល់ឲ្យយើងគ្រប់គ្នា។

[១៣:៤៨:២៩]

**ស៖** សូមទោស ប្រហែលជាសំណួរខ្ញុំវាមិនច្បាស់។ ខ្ញុំចង់ស្វែងយល់ថាតើចំណីអាហារដែលលោកបានហូបនុំង លោកបានមកពីណា? អ្នកណាជាអ្នកយកចំណីអាហារហ្នឹង យកមកកន្លែងដែលយើងត្រូវហូបបាយហ្នឹង? និយាយឲ្យចំថា តើបាយទឹកទាំងអស់ហ្នឹងគេយកមកពីណា?

**ផ៖** នៅការដ្ឋាន និយាយរួម គឺកន្លែងសង្កាត់ៗហ្នឹងគេមានសេដ្ឋកិច្ច ប្រធានសេដ្ឋកិច្ច ហើយនិងមានអង្ករ មានអីជម្រុកគេ សម្រាប់ឲ្យចុងភៅវរៈ គ្រប់វរៈ។ ព្រលឹមឡើងរបបប៉ុន្មានគេហ្នឹងវាល់ឲ្យមកតាមវរៈរៀងៗខ្លួន។ អាហ្នឹងលើសេដ្ឋកិច្ចវរៈទេ អ្នកទៅយកផ្ទាល់ ត្រង់បានប៉ុន្មានៗគេបបរប៉ុន្មានយើងចាំតែដល់ពេលយកាម៉ែលទៅដាក់ គឺចប់។

**ស៖** ប្រធានសេដ្ឋកិច្ចនេះ មកពីថ្នាក់ស្រុក ឬក៏មកពីថ្នាក់តំបន់?

**ផ៖** សេដ្ឋកិច្ចនៅ -- បើតាមខ្ញុំឮឈ្មោះ គឺនៅភូមិជិតគ្នានឹងខ្ញុំដែរ តែគាត់អ្នកតស៊ូអីចឹងទៅគាត់បានកាន់ប្រធានសេដ្ឋកិច្ច ជាស្រីទេ។ គេហៅយាយ ណៃៗ។

**ស៖** ដូច្នេះ កម្មាភិបាលនារីម្នាក់ហ្នឹងគឺទទួលខុសត្រូវទៅលើមនុស្ស ៥-៦០០នាក់ដែលធ្វើការទាំងអស់គ្នានៅទំនប់ហ្នឹង។ តើត្រឹមត្រូវដែរឬក៏អត់ទេ?

**ផ៖** គាត់ក្តាប់សេដ្ឋកិច្ចរួមមួយសង្កាត់ហ្នឹងមានវរបុរស វរនារី វរយុវជន។ បីវរៈហ្នឹង ខ្ញុំមិនដឹងថាស្ថិតិប៉ុន្មានទេ ប៉ុន្តែ បើវរយុវជន វរៈទី២ ខាងដែលខ្ញុំនៅគឺពី ៥-៦០០នាក់។

**ស៖** តើកម្មាភិបាលនារីម្នាក់ដែលលោកទើបតែនិយាយអម្បាញ់មិញហ្នឹង សព្វថ្ងៃហ្នឹងនៅរស់ទេ?

**ផ៖** គាត់បានស្លាប់ពីឆ្នាំ៨០ បាត់ហើយ។

[១៣:៥២:១៩]

**ស៖** ព្រឹកមិញនេះ លោកបាននិយាយសង្ខេបអំពីល្អបម្នាក់ឈ្មោះ លន់ ហើយព្រឹកមិញនោះលោកក៏បាននិយាយថា លោកកម្រនឹងឃើញឈ្មោះ លន់ នេះ នៅឯការដ្ឋានលើកទំនប់ណាស់។ ហើយលន់ ខ្លួនឯងនេះក៏បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា គាត់មិនធ្លាប់បានទៅការដ្ឋានលើកទំនប់ហ្នឹងទេ។ សូមលោកព្យាយាមនឹកឡើងវិញមើល៍ ថាតើលោកធ្លាប់ដែលបានឃើញគាត់នៅឯការដ្ឋានលើកទំនប់ទេ?

**ផ៖** ដូចខ្ញុំរៀបរាប់ពីព្រឹកថា គាត់ច្រើននៅធ្វើការនៅតាមភូមិទាំងប៉ុន្មានហ្នឹងច្រើន ត្រង់ថាទៅការដ្ឋាន ១មករាហ្នឹង ដូចជា មិន -- គាត់មិនសូវឃើញ ឃើញម្តាក់ម្តងហ្នឹង ដូចជាគាត់មានការអីផងយើងអត់ដឹង។

[១៣:៥៤:០៣]

**ស៖** តើលោកចាំថា លោកបានឃើញគាត់នៅកន្លែងណាដែរ? ឃើញនៅក្នុងពេលណា? តើគាត់គ្រាន់តែដើរកាត់ទីនោះ ឬក៏យ៉ាងណា? សូមលោកពន្យល់ឲ្យបានលម្អិតបន្តិចបានទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប។

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។

ខ្ញុំគ្រាន់តែចង់បញ្ជាក់ចំណុចមួយដែល លន់ បានឆ្លើយ។ គឺថា នៅក្នុងចម្លើយរបស់គាត់ហ្នឹងគឺថា គាត់មិនធ្លាប់ដែលបានត្រូវចាត់តាំងឲ្យទៅយាមនៅការដ្ឋានលើកទំនប់ទេ ប៉ុន្តែគាត់ថាគាត់ធ្លាប់បានឃើញ ប៉ុល ពត មកពិនិត្យមើលទំនប់ ១មករា ហើយគេចាត់តាំងឲ្យគាត់រែកដី បីខែដែរនៅទំនប់ ១មករាន៎ុង។ ចម្លើយ គឺថាគាត់ទៅទីនោះ ទៅធ្វើការនៅទីនោះអស់រយៈពេល៣ខែដែរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ចំណុច គឺនៅត្រង់ថា ហាក់បីដូចជាគេចាត់តាំងឲ្យគាត់យាមហ្នឹង មានរយៈពេលកំណត់ ប៉ុន្តែនៅពេលសាក្សីនិយាយថា កម្រឃើញហ្នឹង គឺតើចង់មានន័យថាម៉េច។ ហេតុដូច្នេះឯងទើបជាខ្ញុំជជីកសួរឲ្យសាក្សីឆ្លើយបន្តិចមើល ពាក្យថា “កម្រឃើញ” ហ្នឹង ចង់មានន័យថាម៉េច? ធ្លាប់ឃើញគាត់តែម្តងឬ? តើនៅក្នុងរយៈពេលតែម្តងហ្នឹង លោកចាំអ្វីខ្លះអំពីឈ្មោះនេះ?

[១៣:៥៥:៥៨]

**លោក អ៊ុត សេង៖**

**ឆ៖** ធ្លាប់បានឃើញ ដូចជាដើរកាត់អ៊ីចឹងទៅ គាត់ទៅ គាត់ក្តាប់អ្នកភូមិកងសៅ។ អ៊ីចឹង គាត់មានសិទ្ធិដើរកាត់ទៅរកភូមិដែលមានជំរំនៅក្នុង ឯក្នុងអាងជិតទំនប់១មករាន៎ុង កន្លែងទីតាំងភូមិកងសៅ។ គាត់អាចដើរទៅលេង ឬទៅសួរអីនៅអ្នកភូមិខាងនោះ គឺតែប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវខ្ញុំចូលទៅប្រធានបទថ្មី។ ព្រឹកមិញនេះ លោកបានឆ្លើយថា លោកបានស្តាប់ឮ ប្រជាជននិយាយគ្នាថា ពលករពីរបីនាក់ ត្រូវបានគេយកចេញទៅបាត់ទៅសម្លាប់ចោល ហើយទម្លាក់ចូលក្នុងអណ្តូង។ តើលោកចាំឈ្មោះមនុស្សដែលបាននិយាយអំពីរឿងៗ

សម្លាប់នេះដែរទេ?

**ឆ៖** នៅចាំ គឺគាត់ជាប្រធានវរយុវជន នៅរស់សព្វថ្ងៃ។

**ស៖** លោកដឹងទេថា អ្នកនិយាយរឿងសម្លាប់ហ្នឹង ធ្វើម៉េចបានជាពួកគាត់ហ្នឹង ដឹងអំពីជោគវាសនារបស់មនុស្សបីនាក់នេះ? តើពួកគាត់បានឃើញដោយផ្ទាល់ភ្នែក បានឮដោយផ្ទាល់ភ្នែក ឬក៏យ៉ាងណា? តើលោកដឹងៗថា អ្នកដែលនិយាយនេះ គាត់ដឹងប្រភពនៃការសម្លាប់នេះមកពីណាដែរទេ?

**ឆ៖** ខ្ញុំមិនដឹងទេ គ្រាន់តែបានឮ។

**ស៖** តើលោកចាំទេ ខ្ញុំដឹងថារយៈពេលវាយូរយារណាស់មកហើយ លោកនៅចាំពាក្យពេចន៍ពិតប្រាកដដែលអ្នកទាំងនោះនិយាយទេ?

**ឆ៖** គេៗគ្រាន់តែថា "អូអ្ហ! ទុកក៏មិនចំណេញដែរ ដកចេញចោល ដកចេញក៏វាមិនខាតដែរ។ គឺគេប្រើពាក្យហ្នឹង ហៅថា "សុខចិត្តវាយច្រឡំ កុំឲ្យទុកច្រឡំ"។

[១៣:៥៩:២២]

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែលោកនិយាយអ៊ីចឹង ហាក់ដូចជាទូទៅពេក ប៉ុន្តែតើលោកស្តាប់ពួគេនិយាយជាក់លាក់អីទេ ចំពោះពាក្យពេចន៍ពីរបីម៉ាត់ហ្នឹង? ដូចជាថា ទម្លាក់នៅអណ្តូងនៅកន្លែងណា? ទម្លាក់នៅពេលណា? អ្នកណាជាអ្នកទម្លាក់សពទាំងបីនោះទៅក្នុងអណ្តូង? គឺចំណុចលម្អិតបែបនេះលោកនៅចាំទេ?

**ឆ៖** មិនៗចាំទេ គ្រាន់តែពេលដែលឮហ្នឹង -- សុំសួរម្តងទៀត។

**ស៖** សំណួររបស់ខ្ញុំចង់សួរលម្អិត ចំណុចលម្អិតណាមួយដែលលោកអាចទៅបានអំពីការសន្ទនាគ្នាដែលលោកបានស្តាប់ឮ តើអ្នកទាំងនោះមាននិយាយថា ខ្មោចអ្នកទាំងបីហ្នឹងទម្លាក់ទៅក្នុងអណ្តូងមួយណា? នៅឯណា? អ្នកណាជាអ្នកទម្លាក់? ទម្លាក់នៅម៉ោងប៉ុន្មាន? ហេតុអ្វីបានជាគេសម្លាប់អ្នកទាំងបីហ្នឹង ហើយគេទម្លាក់ទៅក្នុងអណ្តូង? តើលោកចាំចំណុចជាក់លាក់ទាំងនេះខ្លះៗដែរទេ?

**ឆ៖** យើង -- ខ្ញុំមិនចាំទេដល់អត់ចាំសម្តីទាំងអស់ហ្នឹងទេ គ្រាន់ថា ឮថា "ហ៊ឺះ! យប់មិញទម្លាក់អណ្តូងពីរ បីហើយ" បើថាទម្លាក់ឯណានោះ យើងមិនដឹង ភ័យតែខ្លួនឯងផង ប៉ុណ្ណឹង។

**ស៖** ខ្ញុំបន្តទៅសំណួរចុងក្រោយរបស់ខ្ញុំ។ លោកសាក្សី ព្រឹកមិញលោកនិយាយសង្ខេបអំពីដំណើរទស្សនកិច្ចរបស់ប្រតិភូ ចិន។ តើលោកមានចាំឈ្មោះគណៈប្រតិភូចិនដែលទៅធ្វើទស្សនកិច្ចនៅទំនប់១មករានោះដែរទេ?

**ឆ៖** មិនបានចាំទេ តែមុខមិនបានឃើញផង។ គ្រាន់តែដឹងថា "គណៈប្រតិភូមិមកសម្ភោធ គេរែកទឹក បាចដីឲ្យវាស្វាហាប់ឡើង" មេកងប្រាប់បានប៉ុណ្ណឹង។ ចូលទៅក៏យើងមិនបានធ្វើដែរ ឆ្ងាយណាស់ ប្រជាជនច្រើន។

[១៤:០២:៤១]

**ស៖** តើមានគេប្រាប់ឲ្យលោកប្រឹងធ្វើការឲ្យស្វាហាប់បន្តិចដែរទេ នៅពេលដែលប្រតិភូចិនទៅពិនិត្យមើលការដ្ឋានហ្នឹង? តើលោកមានបានដាក់ កាប់ដីដាក់ឲ្យពេញៗបង្គី ហើយរែករត់ដែរឬក៏អត់ទេ ខុសពីថ្ងៃធម្មតាហ្នឹងដែរឬទេ?

**ឆ៖** ដើម្បីទទួលប្រតិភូហ្នឹង គឺស្វាហាប់មែន អ្នកខ្លះញាប់ដៃ ញាប់ជើង មើលទៅវាខុសពីថ្ងៃធម្មតា។

**ស៖** តើពាក្យថា "ស្វាហាប់" នេះ តើរួមទាំងការដាក់ជីក រួមទាំងការកាប់ដី ដាក់ពេញៗបង្គីផងដែរទេ?

**ឆ៖** ត្រូវ ដាក់ពេញៗបង្គី រែកឲ្យលឿនបន្តិច គឺមានស្មារតីភ្ញាក់រឭកខ្លួនឯង។ បើមេក្រុមមេកង ឲ្យយើង ដាក់តែមួយប្រាវអ៊ីចឹងទៅ ដើម្បីបង្ហាញ គឺយើងត្រូវតែអនុវត្តតាម។

**ស៖** សំណួរនេះវាប្រហែលជាវាពិបាកបន្តិច ប៉ុន្តែថាតើលោកអាចញែកឲ្យដាច់ពីគ្នាបានទេ ពីចំនួនដីដែលដាក់ទៅក្នុងបង្គីនៅពេលធ្វើការក្នុងថ្ងៃធម្មតា ហើយនិងចំនួនដីដែលកាប់ដាក់ក្នុងបង្គី នៅពេលដែលប្រតិភូទៅធ្វើទស្សនកិច្ចនៅត្រង់ហ្នឹង។ តើវាខុសគ្នាយ៉ាងម៉េចដែរ លោកប៉ាន់ប្រមាណមើល៍ វាមានថ្ងៃធម្មតាដាក់ប៉ុន្មានគីឡូ? ហើយពេលប្រតិភូទៅមើលហ្នឹង ដាក់ប្រហែលប៉ុន្មានគីឡូ?

[១៤:០៥:០០]

**ឆ៖** គិតគីឡូ -- គ្រាន់ថាថ្ងៃធម្មតាយើងដាក់ម៉ាស្មើបង្គីអ៊ីចឹងទៅ ឬក៏តិចជាងមិនដល់ពេញបង្គីអ៊ីចឹងទៅ ដល់ថ្ងៃទទួលហ្នឹងគឺយើងត្រូវដាក់ឲ្យកំពង់ ហើយរែកឲ្យបានលឿន។

**ស៖** ខ្ញុំដឹងថារយៈហ្នឹង ពីពេលហ្នឹងមកវាយូរយារហើយ ប៉ុន្តែតើលោកអាចស្មានៗមើល៍ថា លោករែកប្រហែលជាដីនៅក្នុងបង្គីហ្នឹងប្រហែលជាប៉ុន្មានគីឡូក្រាមដែរ ក្នុងមួយអម្រែកហ្នឹង?

**ឆ៖** ពិបាកស្មាន។

**ស៖** ខ្ញុំយល់ពិបាកនឹងស្មាន។ តើលោកដឹងទេថា ហេតុអ្វីបានជាទំនប់១មករា និងទំនប់៦មករាហ្នឹងត្រូវបានគេកំណត់ឈ្មោះដាក់លាក់បែបហ្នឹង? ហេតុអ្វីបានជាទំនប់មួយហៅថាទំនប់១មករា

ឯទំនប់មួយទៀតហៅថាទំនប់៦មករា? មានដឹងទេ ម៉េចបានគេហៅឈ្មោះជាក់លាក់បែបនេះ?

**ឆ៖** មិន ខ្ញុំមិនច្បាស់ដែរ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំៗអស់សំណួរហើយ។

[១៤:០៧:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានសូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក សេង ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរខ្លីទេដើម្បីសួរទៅលោក ដើម្បីសុំការបំភ្លឺមួយចំនួនទាក់ទងនឹងចម្លើយរបស់លោក។ ខ្ញុំដូចជាយល់ថា នៅពេលដែលសម្ពោធទំនប់១មករានោះ លោកបានធ្វើការនៅលើទំនប់នោះរួចមកហើយ។ តើខ្ញុំយល់អីចេះត្រឹមត្រូវដែរឬទេ ពេលដែលគេសម្ពោធនោះលោកបានទៅធ្វើការនៅទីនោះហើយ?

**លោក អ៊ុត សេង៖**

**ឆ៖** មែន ពិតមែន។

**ស៖** ខ្ញុំក៏យល់ដែរថា លោកធ្វើការនៅទីនោះតិចជាង៣ខែបន្តិចបន្តួច។ អ៊ីចឹង សំណួរខ្ញុំដូចតទៅនេះ ថាតើបន្ទាប់ពីធ្វើការនៅលើទំនប់១មករានោះហើយ លោកត្រូវត្រឡប់ទៅកន្លែងហ្នឹងវិញ ពេលដែលគេកំពុងតែធ្វើការងារហ្នឹងចប់ហើយ ឬក៏ពេលមិនទាន់ចប់ទេ ពេលកំពុងធ្វើការ ឬក៏ពេលជិតចប់ហើយបានទៅវិញ?

[១៤:០៨:៥៧]

**ឆ៖** កាលនុ៎ងទៅមុនចប់ការដ្ឋាន។ ការដ្ឋាននៅធ្វើរហូតទាល់ចប់ ខ្ញុំទៅមុន។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែសំណួរខ្ញុំនោះ ខ្ញុំចង់ដឹងថាបន្ទាប់ពីធ្វើការនៅទំនប់១មករានោះហើយ

លោកបានត្រឡប់ទៅទំនប់១មករាហ្នឹងវិញ ខ្ញុំមិនដឹងថាហេតុអីបានទៅទេ។ កាលហ្នឹងដូចថាមានពិធីមួយនៅពេលដែលគេធ្វើទំនប់នោះចប់នោះ គេរៀបចំពិធីមួយ។ អ៊ីចឹងខ្ញុំសួរលោកថា លោកមានបានទៅពេលហ្នឹងវិញទេ?

**ឆ៖** កាលចប់ទៅខ្ញុំមិនបានត្រឡប់ទៅ១មករាវិញទេ។

**ស៖** លោកបានឆ្លើយថា ទំនប់នោះធំណាស់ដែរ ហើយដែលមានប្រឡាយដែលលាតសន្ធឹងលើផ្ទៃដីជាច្រើនគីឡូម៉ែត្រ។ អ៊ីចឹងតើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថានៅពេលដែលលោកធ្វើការនៅទីនោះនោះ លោកគ្រាន់តែនៅកន្លែងធ្វើការតូចមួយនៃការដ្ឋានដ៏ធំនោះទេ។ លោកមិនបានផ្លាស់ទី ឬក៏ដំណើរទៅមើលកន្លែងផ្សេងទៀតនៃការដ្ឋានហ្នឹងនោះទេ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ? ខ្ញុំប្រហែលជាត្រូវសួររបៀបផ្សេងវិញ ព្រោះថាអត់ឃើញលោកឆ្លើយ។ សំណួរខ្ញុំនោះ ខ្ញុំចង់ដឹងថា តើលោកយល់ស្របនឹងខ្ញុំទេ ថានៅពេលដែលលោកធ្វើការនៅលើការដ្ឋានហ្នឹង គឺការដ្ឋានទំនប់០មករាហ្នឹង។ លោកធ្វើការតែនៅលើផ្នែកមួយនៃការដ្ឋានហ្នឹងទេ លោកមិនបានធ្វើការនៅលើទំនប់ហ្នឹង ដែលមានប្រវែងរាប់សិបគីឡូម៉ែត្រនៃទំនប់នោះទេ លោកធ្វើការនៅតែកន្លែងលោកតែប៉ុណ្ណោះ។ តើលោកយល់ស្របនឹងខ្ញុំទេ?

**ឆ៖** ពិត ពិតមែន។ ខ្ញុំយល់ស្រប។

[១៤:១១:៣៧]

**ស៖** លោកបានឆ្លើយអម្បាញ់មិញទៅសហភាតារបស់ខ្ញុំ លោកបានពន្យល់ថា ផ្នែកដែលលោកធ្វើការ ថាលោកមិនបានឃើញម៉ាស៊ីនទេ ក៏ប៉ុន្តែក្រោយពីពេលរបបនោះផ្តួលរលំទៅ លោកឃើញមានគ្រឿងចក្រនៅក្នុងព្រៃ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើលោកយល់ស្របនឹងខ្ញុំដែរឬទេ ថាវាអាចដែលនៅផ្នែកដែលលោកធ្វើការនោះ មិនមានគេប្រើគ្រឿងចក្រទេ ក៏ប៉ុន្តែប្រហែលជានៅកន្លែងផ្សេងទៀតនៃការដ្ឋាននោះ ប្រហែលមានការប្រើប្រាស់គ្រឿងចក្រដែលលោកមិនបានឃើញ។

**ឆ៖** យើងមិនដឹង ព្រោះថានៅឆ្ងាយពីគ្នា។ យើងធ្វើការតែម្តុំ។ ព្រោះថាដាច់ទៅ៧៩ គឺឃើញគ្រឿងចក្រមានប៉ុលធំៗ មានអាបេសេតអ៊ីចឹងទៅ កន្លែងគ្រឿងចក្រ គ្រឿងជាង រោងជាងដ៏ធំមួយរបស់ខ្មែរក្រហម។

**ស៖** នៅត្រង់ចំណុចនេះហើយដែលខ្ញុំចង់ត្រឡប់មកនិយាយនេះ ព្រោះថានៅក្នុងចម្លើយរបស់លោក គឺឯកសារ E3/5267, ERN ជាភាសាបារាំងគឺ 00482932, ERN ជាភាសាខ្មែរគឺ 0027

1407, ERN ជាភាសាអង់គ្លេសគឺ 002854-- នៅក្នុងចម្លើយរបស់លោក មានសរសេរដូចតទៅនេះ៖ “គឺទំនប់នេះ ត្រូវបានសាងសង់ពីដីសុទ្ធ ហើយនិងដោយកម្លាំងមនុស្សសុទ្ធសាធ”។ សូមបញ្ចប់ការដកស្រង់។ នេះបើនិយាយអំពីអ្វីដែល -- ដូចគ្រឿងចក្រដែលលោកបាននិយាយបានលើកឡើងអម្បាញ់មិញ ហើយនិងការកត់សម្គាល់របស់ចៅក្រម ឡាវែន៍ ដែលនិយាយថា ទ្វារទឹកទាំងអស់នោះសុទ្ធតែធ្វើអំពីបេតុងនោះ។ អ៊ីចឹង នៅពេលពេលដែលលោកនិយាយថា ទំនប់នេះធ្វើតែពីដី ហើយនិងដោយដៃផ្ទាល់។ អ៊ីចឹង ពេលដែលលោកនិយាយយ៉ាងដូច្នេះ គឺលោកសំដៅតែកន្លែងដែលលោកធ្វើការដោយផ្ទាល់ប៉ុណ្ណឹងទេ។ តើអ៊ីចឹងមែនទេ?

[១៤:១៤:២៩]

**ឆ៖** ពិតជាអ៊ីចឹងមែន ប៉ុន្តែគ្រាន់តែយើងនៅធ្វើការអ៊ីចឹង យើងឮថា “ហ៏! ឯនោះគេធ្វើសំណង់ធំ” ប៉ុនយើងពុំមានសិទ្ធិដើរហើរទៅមើលទៅអី អត់មានទេ។ ប៉ុណ្ណឹង។

**ស៖** ខ្ញុំចង់និយាយអំពីចំណុចមួយទៀតជាមួយលោក គឺទាក់ទងទៅនឹងកិច្ចប្រជុំដែលលោកបានលើកឡើង ដែលលោកបាននិយាយពីកិច្ចប្រជុំពេលធ្វើការរួចហើយនៅលើទំនប់នោះពេលល្ងាចៗ។ អ៊ីចឹង ខ្ញុំចង់ដឹងថា តើនៅក្នុងពេលប្រជុំនោះ មេក្រុមរបស់លោក ឬក៏អ្នកផ្សេងម្នាក់ទៀតមានពន្យល់ពីមូលហេតុថា ហេតុអ្វីបានគេសង់ទំនប់ហ្នឹង លើកទំនប់ហ្នឹងឡើង? ហើយលោកបានឆ្លើយថា អម្បាញ់មិញនេះទៅសហភាតារបស់ខ្ញុំនោះ គឺថាទំនប់ហ្នឹងមានប្រយោជន៍ចាប់ពីឆ្នាំ៧៨ រហូតដល់ទសវត្សរ៍ឆ្នាំ៨០។ អ៊ីចឹង ខ្ញុំចង់សួរលោកថា តើនៅក្នុងកិច្ចប្រជុំដែលលោកបានចូលរួមហ្នឹង គេមានបានពន្យល់ប្រាប់លោកអំពីផលប្រយោជន៍ ឬក៏អត្ថប្រយោជន៍របស់ទំនប់១មករា ហ្នឹងដែរឬទេ?

**ឆ៖** គេពុំមាននិយាយពីផលប្រយោជន៍ ឬក៏អ្វីៗទៀតទេ។ បើនិយាយ គឺនិយាយត្រង់ថា ប្រឹងធ្វើការជាប្រចាំទៅបានហើយ។

**ស៖** ហើយលោកបានចូលរួមកិច្ចសម្ពោធទំនប់ហ្នឹង ហើយលោកបានពន្យល់ថា លោក កាលនោះលោកនៅឆ្ងាយ ក៏ប៉ុន្តែលោកឮសុន្ទរកថា ឬក៏បទឧទ្ទេសនាមតាមមីក្រូដែរ។ តើនៅថ្ងៃនោះ គេមានបានពន្យល់អំពីប្រយោជន៍នៃទំនប់ហ្នឹងដែរឬទេ ឬក៏លោកមិនបានចាំអំពីអ្វីដែលលោកគេនិយាយនៅថ្ងៃសម្ពោធនោះទេ?

[១៤:១៦:០០]

**ឆ៖** ពេលនោះ មិនបានចាំ ហើយក៏ឮមិនច្បាស់ដែរ មិនចាំ។

**ស៖** អត់មានបញ្ហាអ្វីទេ បើសិនលោកមិនចាំទេ អត់មានបញ្ហាអីទេ។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីកំណត់ហេតុស្ដាប់ចម្លើយរបស់លោកមានចំណុចមួយ ដែលលោកបាននិយាយជាមួយសហភាតារបស់ខ្ញុំរួចមកហើយ ក៏ប៉ុន្តែឥឡូវខ្ញុំសូមមើលឡើងវិញនូវអ្វីដែលលោកបាននិយាយនៅពេលដែលលោកផ្ដល់កិច្ចសម្ភាសន៍ឲ្យអ្នកស៊ើបអង្កេតតុលាការខ្មែរក្រហម ព្រោះថាយើងមានប្រតិចារឹកផ្លូវការមានផ្នែកមួយ។ អ៊ីចឹង ខ្ញុំសូមផ្ដល់ផ្នែកមួយចំនួនជូនលោក សូមអានផ្នែកទាំងអស់នោះជូនលោកស្ដាប់ហើយបន្ទាប់មក សួរសំណួរទៅលោក គឺឯកសារ D166.82.1, ERN ជាភាសាបារាំងគឺ 01101656 ERN ជាភាសាខ្មែរគឺ 01101597 ហើយពុំមានប្រតិចារឹកជាភាសាអង់គ្លេសទេ ក៏ប៉ុន្តែគឺជាប្រតិចារឹកខ្សែអាត់ D166/82R ហើយផ្នែកដែលខ្ញុំចាប់អារម្មណ៍នោះ គឺចន្លោះម៉ោង ០១:៣៥:២៥ និងម៉ោង ០១:៣៥:៣០។ ឥឡូវខ្ញុំសូមផ្ដល់ សូមអានជូនលោក នេះគឺជាសំណួរដែលគេសួរលោកដូចតទៅនេះ គឺថាសួរទាក់ទងទៅនឹងការរៀបចំការងារនៅក្នុងក្រុមការងាររបស់លោក សំណួររបស់លោក ហែម ហ៊ីយ ជាអ្នកស៊ើបអង្កេត សួរលោកតទៅនេះ៖ "ពេលដែលចែកជាក្រុម តើគេឲ្យក្រុមម្នាក់លើកឡើងរបៀបយ៉ាងម៉េច? ជាក្រុមបីនាក់ហ្នឹង គេឲ្យលើកប៉ុន្មានម៉ែត្រគូបយ៉ាងម៉េច អីក៏យ៉ាងម៉េច? ហើយចម្លើយរបស់លោកដូចតទៅនេះ៖ "បាទ ដូចជាឥឡូវគេគិតតាមទំហំប្រឡាយ ដូចជាម្នាក់ៗត្រូវថាគេប៉ាន់ថា ម្នាក់ក៏យ៉ាងតិច ក៏១ម៉ែត្រគូបដីក្នុងមួយថ្ងៃ"។ ហើយអ្នកស៊ើបអង្កេតសួរបន្តទៀត៖ "អ៊ីចឹងចំពោះរូបបងផ្ទាល់ តើក្នុងមួយថ្ងៃ គេឲ្យធ្វើ ឬក៏លើកប៉ុន្មានគូប? លោកឆ្លើយថា មួយថ្ងៃ-- ហើយអ្នកស៊ើបអង្កេតសួរបន្ត៖ បងចាំទេមើល៍ទៅ? ហើយចម្លើយរបស់លោកឆ្លើយដូចតទៅនេះ៖ មួយថ្ងៃម្នាក់ៗ មួយម៉ែត្របណ្ដោយប្រឡាយហ្នឹងណ៎ា បើយើងលើកអត់រួចទេ ប៉ុន្តែចេះតែលើកបន្ត ប៉ុន្តែកុំយើងធ្វើពុត ធ្វើអី គេអត់ធ្វើអីយើងទេ។ មិនរួចស្អែកទៀត"។ សូមបញ្ចប់ការដកស្រង់។

សំណួរទី១ របស់ខ្ញុំទាក់ទងទៅនឹងសម្រង់ទី១ នេះដំបូងនេះ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកចាំថា លោកពិតជាបាននិយាយយ៉ាងដូច្នេះទេ ហើយលោកអាចបញ្ជាក់បានដែរទេ ថាបើសិនជាលោករែកមិនរួចតាមផែនការដែលគេកំណត់ឲ្យទេ អាចបន្តនៅថ្ងៃបន្ទាប់បាន?

[១៤:២០:៥៦]

**ឆ៖** ខ្ញុំសូមបញ្ជាក់។ អង្កាល់ដែលខ្ញុំនិយាយ១ម៉ែត្របណ្ដោយហ្នឹង គឺនិយាយក្នុងការដ្ឋានប្រឡាយរបស់សង្កាត់ដែលមានទំហំតូចត្រឹមមាត់៤ម៉ែត្រ ឬក៏ខ្នង៥ម៉ែត្រអ៊ីចឹង គឺគេចែកជាក្រុមពីរបីនាក់ហ្នឹង ១ម៉ែត្រអ៊ីចឹងទៅ ជម្រៅតាមស្ថានភាពដី។ ជម្រៅបាតប្រឡាយ គឺជីក ថា១ម៉ែត្រ វាកើតខ្នង

ប្រឡាយជាស្រេច ដល់គាត់ថា ទេ មិនមែនអាហ្នឹងទេ ជាទំនប់១មករា។ ដល់ជា៦មករា -- ១មករា វិញ ខ្ញុំថា ជាកងខ្ញុំបែកបីក្រុមហ្នឹងគឺលើកជាសមូហភាព មិនបានចែក ឬក៏អីទេ។ បើនិយាយអាតូចហ្នឹងខ្ញុំបាននិយាយមែន។ ចែកថា ១ម៉ែត្រមាត់ប្រឡាយ -- រៀបជីកឱ្យបានជារាងប្រឡាយ ជាខ្នងទំនប់ទាំងអស់ ហើយនិងតាមស្ថានភាពដី រាក់ ឬក៏ជ្រៅ ប៉ុណ្ណឹង។

[១៤:២២:១៣]

**ស៖** អ៊ីចឹងសំណួរសូមបញ្ជាក់លើផ្នែកមួយទៀត ដើម្បីដឹងថា តើយើងយល់ស្របនឹងគ្នាហ្នឹងអត់។ នៅក្នុងខ្សែអាត់ដដែលហ្នឹងលោកបាននិយាយដូចតទៅនេះ៖ "ផែនការងារគេកំណត់ឱ្យនុំង គេឱ្យថា បើសិនជាក្រុមមួយទទួលដី៣ម៉ែត្រ ត្រូវរែកធ្វើហ្នឹង គឺត្រូវឱ្យទាំងបីនាក់ហ្នឹងធ្វើទៅ។ អ្នកស៊ើបអង្កេតសួរ៖ បីនាក់ហ្នឹង? ហើយចម្លើយរបស់លោកថា "រួចមិនរួច ស្អែកទៀត។ គេអត់បង្ខំទេណា៎ ប៉ុន្តែឱ្យយើងប្រឹង"។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួរខ្ញុំសួរអ៊ីចឹង។ ត្រង់ចំណុចនេះដដែល តើលោកនិយាយអំពីប្រឡាយដែលមិនមែនជាប្រឡាយទំនប់១មករា ទេ ឬក៏យ៉ាងណា? ឬក៏ការធ្វើការជាសមូហ-ភាពនេះ វាគេធ្វើអ៊ីចឹងដែរនៅទំនប់១មករា ឬក៏នៅកន្លែងលោកដែលលោកនិយាយពីទំនប់មួយទៀតអម្បាញ់មិញ?

**ឆ៖** អាហ្នឹងខ្ញុំនិយាយពីទំនប់១មករា កង -- ក្នុងកងរបស់ខ្ញុំហ្នឹង គឺគេចែកជាក្រុម បីក្រុមទៀតធ្វើការជាសមូហភាព ទោះបីដូចថា រួចមិនរួច គឺយើងប្រឹងធ្វើសកម្មភាពធម្មតា មិនបាច់សម្រុកទេ។ មិនរួចគឺស្អែក។ គឺមានផែនការបន្ត ឱ្យតែយើងប្រឹង។

**ស៖** ហើយជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា ចំពោះលោកនុំងពិបាកហ្នឹងប៉ាន់ស្មានបរិមាណប៉ុន្មានម៉ែត្រគូបផែនការដែលគេដាក់ឱ្យនុំង ឱ្យក្រុមនីមួយៗហ្នឹង គឺថាលោកពិបាកហ្នឹងប៉ាន់ស្មានណាស់។ មិនដឹងថា គេឱ្យជីកប៉ុន្មានម៉ែត្រគូបទេ ក្នុងមួយថ្ងៃនោះ។ អ៊ីចឹងមែនទេ?

**ឆ៖** មែនហើយ ព្រោះយើងជីករហូតអត់មានឈប់ ទោះបីអ្នកឯងថា ផែនការរួចក៏មិនបានទៅរោង ឬក៏បានឈប់សម្រាកនោះទេ។ យើងធ្វើការតាមលទ្ធភាព ដើម្បីដល់ម៉ោងល្ងាច។ ទោះបីរួចមុនម៉ោងអស់ក៏គ្មានសិទ្ធិទៅអង្គុយប្រាជ្ញ ឬអត់ធ្វើអីទេ។ អ៊ីចឹងយើងសិក្សាទៅ គឺថាធ្វើឱ្យសកម្មឱ្យដល់ម៉ោងផងដែរ។ ប៉ុណ្ណឹង។

[១៤:២៤:០៨]

**ស៖** ខ្ញុំយល់ហើយផ្នែកនេះ ក៏ប៉ុន្តែសំណួរខ្ញុំនោះខុសពីនេះ។ ខ្ញុំដឹងថាលោក -- អម្បាញ់មិញ ខ្ញុំ

ស្មានថាលោកធ្វើការប្រឹងប្រែង ក៏ប៉ុន្តែសំណួរខ្ញុំអម្បាញ់មិញនេះ គឺចង់និយាយថា ចង់ដឹងថាតើជាការលំបាកណាស់ក្នុងការប៉ាន់ស្មាន ដឹងថាតើបរិមាណដែលគេកំណត់ឲ្យធ្វើនោះ ប៉ុនណានោះទេ។ បើសិនជាលោកមិនដឹង មិនអាចឆ្លើយបាន ខ្ញុំអាចចូលទៅចំណុចផ្សេងទៀត ប្រធានបទផ្សេងទៀត។

**ឆ៖** ដូចជាផែនការទទួលពីកងមកយើង -- ពីវរៈ ឬក៏ ពីវរៈអ៊ីចឹង គេឲ្យប៉ុន្មានៗម៉ែត្រអ៊ីចឹងទៅយើងចែកគ្នាទៅមួយកងហ្នឹងវាបានប៉ុន្មានម៉ែត្រ? យើងអង្គុន់ជាបីក្រុមមក យើងធ្វើ មិនដឹងជាថាគិតគូបគិតផុកអីទេ កាលហ្នឹង យើងដឹងតែពីប្រឹងកាប់ធ្វើៗម៉េចថាឲ្យពីរថ្ងៃឲ្យរួច យើងឲ្យរួចពីរថ្ងៃ។ គ្រាន់តែប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមអរគុណ កម្មវត្ថុនៃសំណួរខ្ញុំអម្បាញ់មិញនេះគឺអ៊ីចឹងឯង។ ចំណុចចុងក្រោយដែលខ្ញុំចង់និយាយជាមួយលោក លោកបាននិយាយពីឈ្មោះ លន់ ជាមួយសហព្រះរាជអាជ្ញាអម្បាញ់មិញនេះហើយនិងជាមួយលោក កូប៉េ។ ខ្ញុំដូចជាយល់ថា លោកពន្យល់ថា លន់ ហ្នឹងស្លាប់បីបួនឆ្នាំមកហើយ។ នេះ ជាកំណត់ត្រារបស់ខ្ញុំ។ តើលោកឆ្លើយអ៊ីចឹងមែនទេ? ឬក៏ខ្ញុំហ្នឹងស្តាប់លោក យល់ខុស?

**ឆ៖** ខ្ញុំដូចជាមិនបានថាគាត់ស្លាប់ទេ ប៉ុន្តែវាបាត់មុខគាត់តាំងពីគាត់ជាប់គុក៧៩។ ចេញពី៧៩ជួបគាត់មួយភ្លែត តាំងពីហ្នឹងមក ៨0 អីគឺគាត់អត់ប៊ានទៅភូមិ ព្រោះនៅក្បែរគ្នា។ អ៊ីចឹង បាត់គាត់រហូតទាល់ឥឡូវក៏គ្មានទំនាក់ទំនង ព្រោះគាត់គេច តាម៉ុក។ ត្រង់ថា ស្លាប់ហើយឬនៅ ខ្ញុំដូចជាមិនទាន់បាននិយាយទេ។ ឬក៏ខ្ញុំភ្លេច។

[១៤:២៨:០៨]

**ស៖** សូមត្រឡប់ទៅសំណួរដែលសហភាតាខ្ញុំបានសួរទៅលោកអម្បាញ់មិញនេះ។ ថាតើនៅពេលដែលលោកធ្វើការនៅទំនប់១មករាហ្នឹង លោកធ្លាប់បានឃើញគាត់នៅពេលណាមួយឬទេ? គាត់ធ្វើការនៅក្នុងកងណាមួយដែលគេចាត់តាំងឲ្យលើកទំនប់ដែរ។ តើលោកធ្លាប់បានឃើញគាត់នៅទីនោះដែរទេ?

**ឆ៖** បើឃើញ ឃើញគាត់ដើរមួយភ្លែត គ្រាន់ថាមានកងមានអី គឺមិនដែលដឹង។

**ស៖** នៅក្នុងការបកប្រែហ្នឹង ខ្ញុំឃើញបកប្រែទៅជាពហុវចនៈ អ៊ីចឹង ខ្ញុំសុំសួរបញ្ជាក់លោកថាតើលោកនិយាយពី លន់ ហ្នឹងតែម្នាក់ឯងទេ ឬក៏លោកនិយាយអំពីបុគ្គលណាម្នាក់ទៀតដែរ? អ៊ីចឹងហើយបានជាខ្ញុំឮនិយាយជាពហុវចនៈ។ សូមលោកជួយបញ្ជាក់។

**ឆ៖** គឺនិយាយតែពីឈ្មោះគាត់ម្នាក់គត់។

**ស៖** តើលោកដឹងដែរឬទេថា តើឈ្លបនៅក្នុងឃុំរបស់លោកនោះ ត្រូវបានគេចាត់ទុក -- ចាត់ការឲ្យទៅលើកទំនប់១មករាដែរក្នុងពេលណាមួយនៅពេលដែលគេសាងសង់ទំនប់ ១មករានុ៎ង?

**ស៖** សំណួរចុងក្រោយមុននឹងផ្ដល់វេទិកាទៅមេធាវី គង់ សំអុន សហភាគីរបស់ខ្ញុំ។ នៅថ្ងៃដែលលោកបានឃើញ លន់ នៅលើទំនប់១មករាហ្នឹង គឺលោកមិនបានឃើញគាត់កំពុងតែជីកដីទេ កាប់ដីទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ពិតជាអ៊ីចឹង គាត់គ្រាន់តែដើរកាត់ ឃើញមួយភ្លែត។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ឥឡូវសូមអនុញ្ញាតផ្ដល់វេទិកាជូនលោក មេធាវី គង់ សំអុន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី លោក គង់ សំអុន!

[១៤:៣១:០០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ លោកប្រធាន។ សូមគោរពអង្គជំនុំជម្រះភាគី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក អ៊ុត សេង។ ខ្ញុំមានសំណួរមួយចំនួន សម្រាប់សួរបញ្ជាក់បន្ថែមទៀតទាក់ទងទៅនឹងស្រុកកំណើតរបស់លោក លោកបានជម្រាបជូនអង្គជំនុំជម្រះកន្លងទៅថា លោកមករៀននៅភ្នំពេញ ហើយក្រោយរំដោះ១៧មេសា ១៩៧៥ លោកវិលទៅស្រុកកំណើតរបស់លោកវិញ ហើយស្រុកកំណើតរបស់លោកហ្នឹង គឺនៅភូមិកងសៅ ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ។ ខ្ញុំចង់សួរបញ្ជាក់លោកថា តើឪពុកម្ដាយ បងប្អូនរបស់លោកបង្កើតនៅទីនោះទាំងអស់ដែរទេ នៅពេលដែលលោកត្រឡប់ទៅវិញ?

**លោក អ៊ុត សេង៖**

**ឆ៖** សម័យសង្គ្រាម៧០ គ្រួសារខ្ញុំបានបងស្រីខ្ញុំ គាត់មករស់នៅភ្នំពេញ។ គាត់មានប្ដី កូន ហើយនិងឪពុកខ្ញុំម្នាក់ ហ្នឹងខាងភ្នំពេញ ហើយនិងខ្ញុំ។ នៅខាងស្រុកកំណើត មានតែម្ដាយ និងបងស្រីនៅរស់បែកគ្នា។ ដល់ឆ្នាំ៧៥ ថ្ងៃទី១៥, ១៦ ហ្នឹង ខ្ញុំហ្នឹងកាលនុ៎ង យើងដើរលេង ដូចថានៅផ្ទះនុ៎ង វា

មានបញ្ហាផ្ទះតូច ក៏ដើរមកផ្ទះពូនៅឯទួលគោក ដើរពីគិរីរម្យ មកទួលគោក ថ្ងៃទី១៥។ ១៦ គ្រាប់ផ្ទោងច្រើន។ ១៧ ដាច់។ បងប្អូនកូនក្មួយដូចថា ចាបអត់សំបុកហ្នឹង គ្នាប្រាំនាក់ នាំគ្នាវេចអង្ករ វេចឆ្នាំងព្រោះគេឱ្យចេញពីរបីថ្ងៃ យើងទៅដាក់អង្ករ ហើយក៏ចេញមកតាមផ្លូវជាតិលេខ៥រហូត ទៅដល់ -- មួយខែគត់ ទៅដល់កំពង់ថ្ម។ តែបងខ្ញុំ គាត់មិនដឹងទៅឯណាទេ អត់ -- ខ្ញុំអត់ដឹង។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់បន្ថែមថា ក្នុងគ្រួសាររបស់លោក តាមអ្វីដែលលោករៀបរាប់មកនេះ គឺអាចមើលឃើញថាជាពីរផ្នែក មួយគឺជាអ្នកមូលដ្ឋាន មានម្ដាយរបស់លោក និងបងស្រីរបស់លោក។ ហើយសម្រាប់លោក និងឪពុករបស់លោក អាចចាត់ទុកថាជាអ្នក១៧មេសា។ តើខ្ញុំយល់អ៊ីចឹង ត្រឹមត្រូវទេ?

**ធ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងរបបអាហារ ខ្ញុំចង់សួរបញ្ជាក់លោកថា នៅក្នុងក្រុមធ្វើការ -- កងការងាររបស់លោក តើអ្នក១៧មេសា និងអ្នកមូលដ្ឋាន ហូបរួមគ្នាជាមួយគ្នា ឬមួយក៏មានចុងភៅផ្សេងគ្នា?

[១៤:៣៤:៤៣]

**ធ៖** នៅវរៈយុវជន ហៅថាវរៈទី២ យុវជនដែលមានគ្នាជាងប៉ុន្មានរយនាក់ហ្នឹង គឺមានរបប -- មានចុងភៅតែមួយកន្លែងគត់ ដូចថាចុងភៅធំ សម្រាប់គ្នាទាំងអស់គ្នាទុំង។ ហូប -- មិនហូបរួមទេ តែយើង គេចែកជារបប ហូបឯណា ហូបទៅ ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថាចុងភៅជាអ្នករៀបចំចម្អិនអាហាររួម ហើយបានគេដួសចែកឱ្យពលករម្នាក់ៗ ដោយឡែកពីគ្នា។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ធ៖** ត្រឹមត្រូវបាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់បញ្ជាក់បន្ថែមទាក់ទងរឿងអាហារនេះដែរ ចុងភៅមានរៀបចំម្ហូបដោយឡែក សម្រាប់ក្រុមជាអ្នកមូលដ្ឋាន និងក្រុមជាអ្នក១៧មេសា ហ្នឹងទេ ឬក៏ការដួសចេញពីឆ្នាំងតែមួយដូចគ្នា?

**ធ៖** គឺដួសចេញពីឆ្នាំងតែមួយ គ្រាន់តែគេមូលដ្ឋានឬក៏ជាប្រធានកង ប្រធានវរៈ អ៊ីចឹងទៅមេសេដ្ឋកិច្ចដែលអ្នកដួសហ្នឹងគឺគេ គ្នាគេ គេដំឡើងរបបមួយវែកឱ្យពីរវែកអ៊ីចឹងទៅ។ បើអ្នកមូលដ្ឋានថាមួយវែក -- អ្នក១៧ មួយវែកគឺមួយវែកហើយ ប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ តើលោកបានកត់សម្គាល់ឃើញមានការតវ៉ាពីរឿងរបបអាហារទេ ក្នុងករណីដែលមានការចែករបបមិនស្មើគ្នាបែបនេះ?

**ឆ៖** ពុំមានជនណាមួយហ៊ានតវ៉ា រឿងរបបនេះទេ។

[១៤:៣៧:៤៣]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានថានរណាដែលជា១៧មេសា –ជាអ្នក១៧ មេសា– ហើយទទួលរបបតិចជាងអ្នកមូលដ្ឋានដែរទេ នៅក្នុងក្រុមការងាររបស់លោក? ជាឈ្មោះ បុគ្គល។

**ឆ៖** រឿងនេះ ខ្ញុំមិនច្បាស់ចាំទេ គ្រាន់ថាពេលទៅដួសហ្នឹងគឺចម្រុះទាំងកង ទាំងប៉ុន្មានរយនាក់ ហ្នឹង អ្នកណាទៅដល់មុនដួសមុន ប៉ុន្តែគេអ្នកដួសគេស្គាល់ចាស់ថ្មី ប្រាកដណាស់ ដោយសារសម្លៀក បំពាក់។ ដូចខ្ញុំនិយាយអ៊ីចឹង ថាសម្លៀកបំពាក់អ្នក១៧ បើមិនជ្រលក់ភក់ គេថាយើងនៅប្រកាន់ស្អីអាវថ្មី អាវក្រឡាស្អីអ៊ីចឹងទៅ វាមានបញ្ហាដល់ជីវិត។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងតាមសម្តីរបស់លោក ការបែងចែករបបហ្នឹង គឺអ្នកដួសៗ ជា អ្នកបែងចែកឲ្យខុសគ្នា មិនមានគោលការណ៍បង្គាប់ពីថ្នាក់លើបញ្ជាក់ឲ្យដួសមិនឲ្យស្មើគ្នាបែបនោះទេ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** វាគ្មានគោលការណ៍ពីលើអីទេ គ្រាន់ថាគ្នា -- អ្នកសេដ្ឋកិច្ចហ្នឹងឯង ហើយនិងប្រធានវរៈ ហ្នឹង ជាអ្នកបញ្ហាអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់អំពីវរៈរបស់លោកស្ថិតក្នុងវរៈ២។ តើលោកអាចចាំ បានទេថា វរៈរបស់លោកហ្នឹង ជាវរៈរបស់ស្រុក របស់តំបន់ ឬក៏ភូមិភាគ?

**ឆ៖** វរៈយុវជនគឺវរៈរបស់សង្កាត់កំពង់ថ្មផ្ទាល់ មិនមែនស្រុក ឬក៏ខេត្ត តំបន់អីទេ។

[១៤:៤០:៣៥]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងវត្តបារាយណ៍ជាន់ដែក ខ្ញុំបានឮលោកហៅថា "វត្ត បារាយណ៍សណ្តែក"។ តើឈ្មោះនេះខុសគ្នាយ៉ាងម៉េច លោកអាចបញ្ជាក់បានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក អ៊ុត សេង៖**

**ឆ៖** ភាសាហៅហ្នឹង បើហៅ បើសរសេរគឺបារាយណ៍ជាន់ដែក ប៉ុនដល់យើងខ្មែរយើងហៅបារាយណ៍សណ្ដែកជាទូទៅ វារត់មាត់។ ដូចហៅតាសក់ ឧទាហរណ៍។ ត្រសក់ ហើយមិនអាចហៅត្រសក់ទេ ហៅ តាសក់ៗ ប៉ុណ្ណឹង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងទៅនឹងសក្ខីកម្មរបស់លោក លេខ E3/5767 សូមបញ្ជាក់ម្ដងទៀត E3/5267, ERN ជាភាសាខ្មែរ 00271412, ជាភាសាអង់គ្លេស 00282358, ជាភាសាបារាំង 00482936។ ខ្ញុំសូមដកស្រង់ នៅពេលដែល -- សំណួរសួរទាក់ទងទៅនឹងមេធំៗដែលធ្លាប់មកមើលការដ្ឋានដែរឬអត់? ហើយចម្លើយរបស់លោកៗបានឆ្លើយថា សូមដកស្រង់៖ “ពេលមួយនោះគឺមានមេភូមិភាគឈ្មោះ កែ ពក មកសម្ពោធការដ្ឋានទំនប់១មករា”។ សូមចប់ការដកស្រង់។ ខ្ញុំចង់សួរបញ្ជាក់លោកថា តើឈ្មោះ កែ ពក នេះជាប្រធានភូមិភាគ ជាអ្នកមកសម្ពោធ ឬក៏អ្នកផ្សេង? លោកអាចបញ្ជាក់គោលជំហរ ឬការចងចាំរបស់លោកទាក់ទងនឹងពេលសម្ពោធនោះបានទេ?

**ឆ៖** អង្កាល់មកសម្ពោធហ្នឹងគ្រាន់តែថា ហ៎!មានអ្នកធំ មានអង្គការ។ និយាយទៅអង្គការៗធំមកសម្ពោធទំនប់១មករា ហើយមានចិតមានអីចឹង។ តែដែលឮឈ្មោះហ្នឹងគឺ ពកៗ ហ្នឹងគឺឮឈ្មោះតាំងពីហ្នឹងដែរ។ ត្រង់ថាអ្នកណាផ្សេងទៀត អត់ស្គាល់ឈ្មោះ ប៉ុណ្ណឹងឯង។

[១៤:៤៤:០២]

**ស៖** បាទ អរគុណ។ លោកដឹងដោយរបៀបណា ដែលថា កែ ពក ជាអ្នកមកសម្ពោធទំនប់១មករា?

**ឆ៖** ព្រោះ តាពក គាត់នៅៗប្រចាំការ ដូចថាមានប៉ុស្តិ៍គាត់ អ៎! ថាមានផ្ទះគាត់នៅនឹងទំនប់១មករា គាត់ឧស្សាហ៍ចេញចូលៗនៅទំនប់១មករា។ ដល់អីចឹងឮឈ្មោះគាត់ច្រើន។ គ្រាន់ថារូបភាពមុខមាត់ អត់ដែលស្គាល់។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់កន្លងមកទាក់ទងទៅនឹងការងារនៅទំនប់១មករា ហើយមានពេលខ្លះលោកបានបញ្ជាក់ពីការងារដែលធ្វើនៅតាមប្រឡាយរបស់សង្កាត់ មិនមែនជាទំនប់ធំ១មករានោះទេ ហើយមុននេះ ក៏លោកបានបញ្ជាក់អំពីប្រវែងទំនប់១មករា ដែលរាប់បញ្ចូលទាំង ទំនប់៦មករាផង មានប្រវែង៦០គីឡូម៉ែត្រ។ ខ្ញុំចង់សួរលោកថា តើការកំណត់នូវប្រវែងទំនប់១មករា ចាប់ពី

ចំណុចណាដល់ចំណុចណា ហើយមានប្រវែងប៉ុន្មានគីឡូម៉ែត្រដែរ លោកអាចជម្រាបបានទេ?

**ឆ៖** ខ្ញុំអាចជម្រាបបាន តែអានេះវាជា ហៅថាដល់ឆ្នាំ៩០ហើយទេ បានយើងដឹងថាទំនប់១មករាមានប្រវែងប៉ុន្មាន ដល់យើងលាតផែនទីមើលទៅ ហើយនិងវាស់វែង វាទប់ស្ទឹងពីរ ស្ទឹង១មករា និងស្ទឹង៦មករា ហើយប្រវែងវា បើបូកទាំងពីរហ្នឹងទៅ៦០គីឡូម៉ែត្រជាង។ អាហ្នឹងយើងដឹងក្រោយរឿងឆ្នាំពី៩០អីហ្នឹងឯង បានដឹង។ នៅពេលកំពុងអវត្តផែនការ គឺយើងមិនដឹងថាគេជីកត្រង់ណា បែរមុខទៅណានោះ អត់ដឹងទេ។

**ស៖** លោកអាចបញ្ជាក់តែចំពោះទំនប់១មករាបានទេ ប្រវែង ហើយនិងចំណុចចាប់ផ្ដើមប្រវែងប៉ុន្មានគីឡូម៉ែត្រ? ហើយចំណុចចាប់ផ្ដើម ហើយនិងបញ្ចប់វិញត្រឹមណា?

**ឆ៖** បើវាស់ជាក់ស្ដែងពីសំណាង់ធំ សំណាង់១០ទ្វារ ទៅស្ទឹង៦មករា មានប្រវែង៧គីឡូម៉ែត្រ។ ពីសំណាង់ធំឆ្ពោះទៅស្រុកបារាយណ៍ គឺមានចម្ងាយ៣២គីឡូម៉ែត្រ ទៅដល់ព្រំដែនខេត្តកំពង់ចាម។

[១៤:៤៧:២១]

**ស៖** បាទ សូមអរគុណ។ ចុះចំណុចដែលលោកធ្វើការនៅសម័យកម្ពុជាប្រជាធិបតេយ្យ លោកធ្វើការនៅត្រង់ចំណុចណា លោកអាចចាំបានទេ ក្នុងពេលឥឡូវនេះ?

**ឆ៖** ខ្ញុំនៅចាំបាន គឺគេហៅតំបន់ត្បែងកោង។ ត្បែងកោងហ្នឹង គេមានសំណាង់មួយ គេហៅថាសំណាង់ទឹកវិល គឺចាប់ពីសំណាង់ទឹកវិលទៅ គឺកង ឬក៏វរៈទី២ ទទួល ឧទាហរណ៍ថា ទទួលប៉ុន្មានម៉ែត្រអីចឹងទៅ គឺចែកគ្នាធ្វើហ្នឹង នៅក្បែរទឹកវិលហ្នឹង ត្បែងកោង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរចុងក្រោយមួយ ទាក់ទងទៅនឹងឈ្មោះ លន់ ដែលលោកបានរៀបរាប់កន្លែងមកនេះ។ លោកបញ្ជាក់អំពីឈ្មោះ លន់ ជាឈ្លប និងមានការងារពាក់ព័ន្ធទៅនឹងការចាប់ខ្លួនមនុស្សមួយចំនួន ហើយក៏លោកបានរៀបរាប់អំពីឈ្មោះ លន់ ត្រូវតុលាការចាប់ជាប់ពន្ធនាគារ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា លោកដឹងថាឈ្មោះ លន់ នេះ ត្រូវជាប់ពន្ធនាគារពីពេលណា ដល់ពេលណាទេ?

**ឆ៖** ឈ្មោះនេះ ឈ្មោះ លន់ នេះ គេចាប់នោះ ខ្ញុំមិនចាំទេ គ្រាន់ថាជួបសម្ដីអ្នកគុកកំពង់ធំនុ៎ងថា ហ៎! លន់ នោះ គឺគេចាប់ដាក់គុកហើយ។ ខ្ញុំក៏ថា បើជាប់គុក រស់ហើយគាត់នោះ។ ខ្ញុំគ្មានគំនុំគុំកួនអីទេ គ្រាន់តែថា អ្ហ៎! ជាប់គុករស់ហើយ។ ប៉ុណ្ណឹង។ ប៉ុន្តែបើចេញទៅវិញ ខ្ញុំមិនចាំ ប្រហែលជា៨៦ ឬក៏៨៥ គាត់បានចេញហើយ គាត់បានមកលេងភ្លេងការឲ្យភូមិខ្ញុំបានម្ដងទៀត។ ដល់ក្រោយ ឡើង

គាត់បែបភ័យ ព្រោះទៅឃើញ សុទ្ធតែអ្នកថ្មី ហៅថា ពួក១៧ នៅក្បែរហ្នឹងច្រើន។ គាត់សឹងតែមិនបានកូតទ្រ សឹងតែនឹងរត់ត្រឡប់មកវិញ ហើយតាំងពីនោះមក ក៏បាត់គាត់រហូត។

**ស៖** សូមអរគុណ។ លោកចាំបានទេថាឈ្មោះ លន់ បានបាត់ចេញពីភូមិ ទីកន្លែងរបស់លោកហ្នឹងនៅពេលណា? ឆ្នាំណាដែរទេ ចុងក្រោយ មុនពេលដែលជាប់ពន្ធនាគារ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក អ៊ុត សេង៖**

**ឆ៖** ដូចចុងឆ្នាំ៧៨ ដូចថាមានការឮសូរពីនេះ ពីនោះ កងទ័ព ហើយចាប់ពីថ្ងៃឮសូរហ្នឹងខ្លាំងឡើងៗ គឺសង្កាត់ក៏ដោយ សេដ្ឋកិច្ចសង្កាត់ក៏ដោយ អ្នកធ្វើការនៅសង្កាត់ហ្នឹង គឺរត់អស់ហើយ។ កងកម្លាំង -- កងវរៈអីហ្នឹង គឺរត់បែកគ្នាទៅផ្ទះរៀងខ្លួន។ ពុំមានអ្នកណានៅនឹងកន្លែងនោះទេ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោក អ៊ុត សេង។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

[១៤:៥១:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ សវនាការនៅថ្ងៃនេះបានចប់មុនពេលកំណត់ សាក្សីបម្រុង 2-TCW-887 ដោយគាត់មានបញ្ហាសុខភាព គាត់ធ្វើដំណើរមកពីទីឆ្ងាយ មកកាន់អ.វ.ត.ក នៅថ្ងៃនេះ ដែលជាហេតុមិនអាចឲ្យអង្គជំនុំជម្រះធ្វើសវនាការផ្ដើមស្ដាប់សក្ខីកម្មរបស់គាត់នៅរសៀលនេះបាន អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការកិច្ចសវនាការសម្រាប់ថ្ងៃនេះត្រង់នេះ សវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បត្តិ៍ ទី០៤ ខែមិថុនា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-887 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ ហើយអង្គជំនុំជម្រះសូមអរគុណលោក អ៊ុត សេង ដែលបានចំណាយពេលដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃកន្លះមកនេះ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ការផ្ដល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ។ វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់

ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន ហើយនិងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៤:៥២:៥៥]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក អ៊ុត សេង វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់ចង់ទៅបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៥៣ នាទី)*